# ការសម្ភាសរបស់អ៊ុំ ហួត ទ្រី

**ក៖ អ្នកសម្ភាសឈ្មោះ ឡេង ធារី** **ខ៖ អ្នកត្រូវគេសម្ភាសឈ្មោះ ហួត ទ្រី**

ក៖ អូខេ! អញ្ចឹងជាដំបូងអរគុណអ៊ុំដែលបានឱ្យខ្ញុំដើម្បីធ្វើការសម្ភាសអ៊ុំនៅក្នុងថ្ងៃហ្នឹង ហើយដើម្បីសួរអំពីជីវប្រវត្តិខ្លះរបស់អ៊ុំទាក់ទងនឹងជីវិតរបស់អ៊ុំ ពីក្រុមគ្រួសារ ហើយដូចខ្ញុំបានប្រាប់ពីដើមគឺជាគម្រោងរបស់សាលាប៊ីវាយយូ ដែលមានឈ្មោះថាគម្រោងប្រវត្តិផ្ទាល់មាត់នៃជូនជាតិខ្មែរ ហើយអញ្ចឹង ខ្ញុំធ្វើការសម្ភាសអ៊ុំនៅក្នុងថ្ងៃហ្នឹងគឺនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨។ ហើយខ្ញុំឈ្មោះឡេង ធារី ខ្ញុំជាអ្នកធ្វើការសម្ភាសអ៊ុំនៅក្នុងថ្ងៃហ្នឹង ហើយការសម្ភាសនេះត្រូវបានធ្វើឡើងនៅក្នុងអគារមណ្ឌលកំពង់ចាម ហើយអញ្ចឹងសុំអ៊ុំប្រាប់ឈ្មោះ អ៊ុំមានឈ្មោះអីដែរ ទាំងនាមត្រកូល?

ខ៖ ខ្ញុំឈ្មោះហួត ទ្រី។

ក៖ ហួត ទ្រី!

ខ៖ ហ្នឹងហើយ!

ក៖ ហើយ...

ខ៖ ជាទីប្រឹក្សាទីមួយមណ្ឌលកំពង់ចាម។

ក៖ អូខេ! ហើយអ៊ុំដូចជាមានឈ្មោះអីហៅក្រៅផ្សេង ក្រៅពីឈ្មោះហ្នឹង?

ខ៖អត់ទេ! អត់មានទេ!

ក៖ ពីក្មេងមកអីក៏អត់មានឈ្មោះផ្សេងដែរអ៊ុំន៎?

ខ៖ អត់ទេ!

ក៖ ឈ្មោះហ្នឹងតែម្តង។ នៅក្នុងអត្តសញ្ញាប័ណ្ណក៏អញ្ចឹងដែរ?

ខ៖ ធ្វើតែម្តងទេអត្តសញ្ញាប័ណ្ណ។

ក៖ ប៉ុន្តែឈ្មោះហ្នឹងដែរ? ដូចគ្នា?

ខ៖ ដដែល!

ក៖ ហើយចុះអ៊ុំសព្វថ្ងៃអាស័យដ្ឋានបច្ចុប្បន្នអ៊ុំរស់នៅទីណាដែរ?

ខ៖ អូ! នៅភូមិទី៦ សង្កាត់វាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម?

ក៖ ហើយអ៊ុំចុះស្រុកកំណើត ស្រុកកំណើតអ៊ុំ?

ខ៖ ស្រុកកំណើតនៅត្រពាំងជ្រៃ ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

ក៖ អញ្ចឹងភូមិត្រពាំងជ្រៃ?

ខ៖ បាទ! ភូមិត្រពាំងជ្រៃចម្ងាយពីកំពង់ចាមប្រហែលជា១០គីឡូ។

ក៖ ចាស! អញ្ចឹងអ៊ុំកើតនៅទីហ្នឹង អ៊ុំន៎?

ខ៖ ហ្នឹងហើយ។

ក៖ ចឹងអ្នកស្រុកកំពង់ចាម។ ហើយមួយទៀតអ៊ុំចាំថ្ងៃខែឆ្នាំកំណើតដែលអ៊ុំកើត?

ខ៖ ថ្ងៃខែ ០៥ ០៤ ១៩៥២។

ក៖ ចឹងបានន័យថាថ្ងៃ០៤ ខែឧសភា។

ខ៖ ហ្នឹងហើយ! ថ្ងៃទី០៤ ខែអឺ...ថ្ងៃទី០៥ ខែមេសា...

ក៖ អូ! ០៥ មេសា ១៩៥២។ ចុះឆ្នាំខ្មែរ? អ៊ុំឆ្នាំអីដែរ?

ខ៖ ឆ្នាំខ្មែរ អង្កាល់នោះឆ្នាំ មើល ខាល ថោះ រោង ប្រហែលជាឆ្នាំថោះ។

ក៖ ឆ្នាំថោះអ៊ុំនោះ។ ហើយអឺម...អ៊ុំកើតឆ្នាំថោះ អញ្ចឹងមកដល់ឥឡូវអ៊ុំមានអាយុប៉ុន្មានហើយអ៊ុំ?

ខ៖ ៦៨ហើយ។

ក៖ ៦៨អ៊ុំនោះ។

ខ៖ ហ្នឹងហើយ!

ក៖ ចង់សួរអ៊ុំនៅក្នុងក្រុមគ្រួសារអ៊ុំ អ៊ុំមានបងប្អូនប៉ុន្មាននាក់?

ខ៖ ខ្ញុំមានបងប្អូន៧នាក់ ស្រី៣ ប្រុស៤។

កៈ អ៊ុំជាកូនទីប៉ុន្មានអ៊ុំ?

ខៈ ហើយខ្ញុំជាកូនពៅ។ ហើយបច្ចុប្បន្នហ្នឹង បងៗខ្ញុំត្រូវបានស្លាប់អស់ហើយ។

កៈ សល់តែអ៊ុំមួយចឹងណោះ?

ខៈ អត់ទេ! បងប្រុសខ្ញុំ៣នាក់ស្លាប់អស់ហើយ ហើយស្រី២នាក់ក៏ស្លាប់ដែរ នៅសល់...អូ! ស្រីមួយស្លាប់ នៅស្រីមួយដែលបងគេបង្អស់ និងស្រីពៅបន្ទាប់ពីខ្ញុំ បន្ទាប់ពីបងខ្ញុំមក ត្រូវជាបងខ្ញុំ។

កៈ ចាស! ហើយអ៊ុំចាំឈ្មោះពួកគាត់ទាំងអស់គ្នា ហើយនិង ពេលគាត់កើតទេ?

ខៈ អូ! កើតអត់ចាំទេ។ បើឈ្មោះចាំ។

កៈ ចាំ អ៊ុំសុំប្រាប់ឈ្មោះពួកគាត់បន្តិតមក?

ខៈ នែ៎ឈ្មោះបងស្រីទីមួយ ឈ្មោះ យូ ទៀង គាត់ឥឡូវប្រហែលជាអាយុជាងប៉ែតហ៊ា។

កៈ ចាស!

ខៈ ហើយបងប្រុសទី២ឈ្មោះ ហាង ស៊ា គាត់ស្លាប់ហើយ។

កៈ ទាំងនាមត្រកូលអ៊ុំ?

ខៈ បាទ?

កៈ ទាំងត្រកូលហ៎ោ?

ខៈ ថាម៉េច?

កៈ ទាំងត្រកូលរបស់គាត់ហ៎ោ?

ខៈ អត់ទេ ត្រកូលដាក់ខូវ។ ខូវ យូទៀង ខូវ ហាងស៊ា ហើយមួយទៀត ខូវ ហាងស៊ុនក៏ស្លាប់ដែរ។ ហើយបន្ទាប់មកទៀត ខូវ ហាងងាន់ ក៏ស្លាប់ដែរ ខូវ យូអៀង ក៏ស្លាប់ដែរ ហើយបន្ទាប់មក ខូវ យូស្រួយ នៅរស់ទេ ហើយបន្ទាប់មកខ្ញុំ។ ហើយពួកគាត់ត្រកូលដូចគ្នាទាំងអស់ ហើយខុសប្លែកតែអ៊ុំមួយដែលត្រកូលខុសគេ។ អ៊ុំហ្នឹងកាលសម័យ ពុល ពត អ៊ុំលាក់ប្រវត្តិរូបហ៎ា ដូរដូរដាក់ហួតហ្នឹង ខ្ញុំចំនាំខ្លួនខ្ញុំ ជីតាខ្ញុំហ្នឹងឈ្មោះហួត ប៉ុនខូវ ហ្នឹងគេហៅត្រកូលហ៎ា ចឹកហ្នឹងត្រកូល ខ្មែរ បើតាមត្រូវគេឱ្យដាក់ខូវទេ ប៉ុន្តែខ្ញុំដើម្បីលាក់ពីអាប៉ុល ពត ហ្នឹង ខ្ញុំដាក់ខូវវិញ... អូ!

ដាក់ហ្វូតវិញ។ ហើយក្នុងព្រះវិហារហ្នឹងក៏នៅតែហ្វូតដដែលចឹង ខ្ចិលដូរចុះឡើងហើយ។ ព្រោះការងាររដ្ឋយើងធ្វើការហ្នឹង គឺយើងដាក់ហ្វូតដែរ។

ក៖ ចឹងអ៊ុំឆ្នាំដែលអ៊ុំដូរត្រកូលហ្នឹង? ប៉ុល ពត?

ខ៖ ដូរត្រកូលហ្នឹងឆ្នាំ ៧៩ហ្នឹង។

ក៖ ៧៩អ៊ុំន៎!

ខ៖ ៧៩ បានដាច់ពីប៉ុល ពត មកហ្នឹង គេធ្វើប្រវត្តិរូបតាមនេះ ប្រធានក្រុមគេដើរសួរ ហើយចឹងខ្ញុំដាក់ហ្វូតវិញ។

ក៖ ចាស អូខេ! ហើយដូចជាជាមួយបងប្អូនអ៊ុំ ដូចជាអ៊ុំចាំអីសាច់រឿងអីល្អៗដែលអ៊ុំមានជាមួយបងប្អូន ដូចពីក្មេងមកណាអ៊ុំ? ដូចថាអ៊ុំជាមួយបងប្អូនចូលចិត្តលេងអី អីៗចឹងហាំណាំ មានទេអ៊ុំ?

ខ៖ ដូចលក្ខណៈក្មេង វាដូចធម្មតា ដូចតែក្មេងដ៏ទៃចឹង វាធម្មតា វាលេងបែបកូនក្មេងចឹងណាំ។

ក៖ ដូចមានអីដែលអ៊ុំឧស្សាហ៍លេងជាមួយបងប្អូនអ៊ុំអីចឹងហាំណាំ? មានទេ?

ខ៖ ទេ ដូចខ្ញុំកូនពៅ វាមិនសូវនែំទៅលេងជាមួយបងអាម៉េចទេ។ អត់ទេ! វា អាគេបង យើងប្អូន វាដូចថាយើងឋានទាបជាងហាំ។

ក៖ ចុះមានដូចជាអ៊ុំមានចងចាំអីខ្លះពីពួកគាត់ បើគិតពីបងប្អូនវិញ? មានអនុស្សាវរីយ៍អីដែលអ៊ុំគិតថាអ៊ុំចងចាំពីពួកគាត់មក?

ខ៖ ចងចាំមានតែអញ្ចេក កាលខ្ញុំធំហើយ នេ៎ក! មិនធំទេ នៅតូចម្ដាយខ្ញុំទៅផ្សារអីចឹង ម្ដាយតែងតែឱ្យគាត់(បងៗ)មើលខុសត្រូវខ្ញុំហាំ ហើយអញ្ចឹងគាត់តែងតែយោលអង្រឹងឱ្យយើងដេកហាំ តែពេលយោលទៅ គាត់បំពេរអីចឹង អានេះអង្គាល ប្រវត្តិអនុស្សាវរីយ៍ហាំ ប៉ុន្តែយើងនៅតូច របៀបថាក្មេង វាម៉្ញិកម៉្ញក់អាណាំ គេបំពេរហើយក៏មិនព្រមបាត់យំ នៅតែម៉្ញិកម៉្ញក់ហាំណាំ ចង់ឱ្យគេធ្វើម៉េចជាមួយយើង ឱ្យរឹតតែខ្លាំងឡើងហាំ ប៉ុនតាមពិតជាហ្នឹងជាចរិកក្មេងទូទៅតាមមើល។

ក៖ ចុះអ៊ុំថានៅសល់បងមួយអ៊ុំហោំ ដែលគាត់នៅរស់?

ខ៖ សល់បងស្រីមួយ តែគាត់ឥឡូវវង្វេងវង្វាន់ ជួនស្គាល់ ជួនអត់។

កៈ អាយុប៉ុន្មានហើយអ៊ុំ?

ខៈ ជិត៩០ហើយ។

កៈ អូ អាយុច្រើនហាអ៊ុំនេ់!

ខៈ ហ្នឹងហើយ។

កៈ គាត់រស់នៅណាឥឡូវអ៊ុំ?

ខៈ ឥឡូវនៅអណ្តូងក្វាន ខាងលិចភ្នំពេញ។

កៈ ខេត្ត ស្រុក ភូមិ ឃុំ ខេត្តអីគេអ៊ុំ?

ខៈ អណ្តូងក្វាន អាហ្នឹងសង្កាត់ស្អីគេទេ ខ្ញុំមិនទេ ព្រោះនៅភ្នំពេញអត់សូវស្គាល់ទេ។

កៈ ប៉ុននៅភ្នំពេញអ៊ុំន៎?

ខៈ ហ្នឹងហើយនៅភ្នំពេញ។ នៅភ្នំពេញជាមួយកូន។

កៈ ចាស! អញ្ចឹងសល់គាត់មួយ ហើយចុះដូចទាក់ទងនឹងរឿង ឪពុកម្តាយ។ ឪពុកម្តាយអ៊ុំគាត់ឈ្មោះអីដែរ?

ខៈ ឪពុកខ្ញុំឈ្មោះ លាង។

កៈ ទាំងត្រកូលរបស់គាត់អ៊ុំ?

ខៈ បាទ!

កៈ ទាំងត្រកូល?

ខៈ ខូវ គុណលាង ហើយម្តាយខ្ញុំឈ្មោះ ហ្វួត គ្រាន់តែយកជីតា យកឪពុកទេណា ព្រោះខ្មែរអីខ្ញុំអត់ចាំទេ។ ខ្ញុំសរសេរប្រវត្តិរូបគាត់ដាក់ ហ្វួត គីមលាន់។ គីម លាន់ ហា។

កៈ ចាស! ហើយអ៊ុំចាំពេលដែលគាត់កើតអី ចាំទេអ៊ុំ?

ខៈ អត់ចាំទេ! ប៉ុន្តែខ្ញុំធ្វើអាពងប្រវត្តិខ្ញុំគិតតែថាតើគាត់ការនៅឆ្នាំណា? ខ្ញុំគិតថាគាត់ការនៅអាយុ២៥ ចឹងណា។

កៈ ចាស។

ខ៖ ហើយចឹងគាត់ត្រូវបានមួយឆ្នាំក្រោយមក គាត់អាយុ២៦អី ខ្ញុំគិតថាគាត់បានកូនបងមួយគាត់កូនមួយចឹងណា៎។

ក៖ ចាស!

ខ៖ អញ្ជឹងកូនមួយខាងលើគេហ្នឹង យើងស្គាល់ឆ្នាំអាយុគាត់។ អញ្ចឹងយើងបន្ថែម២៥ឆ្នាំ ២៦ឆ្នាំទៅលើអាកូនបងនឹងទៅ យើងឃើញអាយុគាត់កើតហើយ។ អាហ្នឹងតាមវិធីយើងរកហា៎ បើមិនធ្វើចឹងយើងរកអត់ឃើញ។

ក៖ ចុះដល់ពេលអ៊ុំរកហ្នឹង គាត់កើតប្រហែលឆ្នាំណា? ពេលអ៊ុំបូកដកគុណចែកទៅ?

ខ៖ អឺម ដូចអត់ចាំទេ តែខ្ញុំសរសេរក្នុងសៀវភៅ ក្នុងសៀវភៅបានខ្ញុំនេះ ព្រោះយើងគិតមាត់ទទេ ខ្ញុំសរសេររួចហើយអាពង្សប្រវត្តិ គាត់ឆ្នាំណា ម្ដាយខ្ញុំឆ្នាំណា អាយុប៉ុន្មានដែលគាត់កើតយើងលៃតាមដូចខ្ញុំនិយាយមិញចឹង។ ព្រោះបើមិនចឹង យើងរកអត់ឃើញទេ ព្រោះមានពីណាមកប្រាប់យើង បើគាត់ស្លាប់អស់ហើយ។

ក៖ ចាស! អញ្ជឹងពួកគាត់ស្លាបអស់ហើយអ៊ុំន៎?

ខ៖ បាទ!

ក៖ គាត់ស្លាប់ពីឆ្នាំណាមក? ហើយគាត់អាយុប៉ុន្មានពេលគាត់ស្លាប់?

ខ៖ ឆ្នាំគាត់ស្លាប់ ម្ដាយខ្ញុំឆ្នាំ១៩៧៥។ ឆ្នាំ៧៥ហ្នឹង គាត់ឈឺសម័យប៉ុលពត គាត់ឈឺនៅណុងស្លាប់ទៅ ហើយឪពុកខ្ញុំនេះ ឪពុកខ្ញុំដូចមួយពាន់...ខែ៥ មួយប្រាំបួនរយប៉ុន្មានទេនៀក មួយប្រាំបួនរយ អ៎ូ ២០០៥។

ក៖ ចឹងគាត់ទើបតែស្លាប់៣ឆ្នាំមុនចឹង?

ខ៖ ហ្អេ៎ ២០០៥ បីឆ្នាំអី ឥឡូវ ២០១៨ហើយ។

ក៖ អូ! ១៣ឆ្នាំហើយ។

ខ៖ ១៣ឆ្នាំហើយ មានតែលើសផង។

ក៖ ចាស! ហើយកាលគាត់ស្លាប់ហ្នឹង គាត់អាយុប៉ុន្មានដែរអ៊ុំ?

ខ៖ គាត់អាយុ៩៤។

កៈ ហ៊ឹម បានច្រើន!

ខៈ បាទ!

កៈ គាត់ស្លាប់ដោយសារចាស់ជរាអ៊ុំណ៎?

ខៈ ហ្នឹងហើយ ជរាពាធ៏។

កៈ ចាស! ជរាពាធ៏។ ចុះម្ដាយអ៊ុំចឹងដែរឬក៏ម៉េច?

ខៈ ម្ដាយខ្ញុំឈឺ។

កៈ ឈឺ! ហើយពេលគាត់ស្លាប់ហ្នឹងគាត់អាយុប៉ុន្មានអ៊ុំ? បានអាយុប៉ុន្មានដែរបានគាត់ស្លាប់?

ខៈ អាយុប្រហែលជា៦០ឆ្នាំទេហ្អែ។

កៈ អូ តិចដែរណ៎អ៊ុំ។

ខៈ តិចហ៎ កាលណុងគាត់ឈឺហ៎ា គាត់ដូចពុកឆ្អឹង។

កៈ អូ! ហើយចុះឪពុកម្ដាយអ៊ុំដូចជា អ៊ុំចងចាំអីពីពួកគាត់?

ខៈ អូ! ខ្ញុំចាំច្បាស់ត្រង់ថាឪពុកម្ដាយខ្ញុំគាត់មនុស្សល្អណាស់ ដែលយើងជាកូនសុំយកគាត់គម្រូណា៎។

កៈ ចាស!

ខៈ ហើយខ្ញុំនិយាយចឹងហ៎ា អ្នកនៅក្នុងភូមិក៏ស្រឡាញ់គាត់ដែរ ព្រោះគាត់មនុស្សចេះឈឺឆ្អើលម៉ង។ ឧទាហរហ៍ អ្នកឃ្វាលគោហ៎ា ពេលម៉ោង១១អី គេតែងយកគោទៅឱ្យទឹកហើយ ឱ្យទឹកហ្នឹងនៅអណ្ដូងទឹកមួយ អណ្ដូងទឹកហ្នឹងនៅដីគេ តែទល់មុខផ្ទះយើងហ៎ា រួចពេលណាឱ្យទឹក គោវាតែងតែជុះអាចម៍ នៅក្បែរៗហ្នឹង។

កៈ ក្បែរអណ្ដូងទឹកហ្នឹង?

ខៈ ក្បែរអណ្ដូងហ្នឹង រួចគាត់អត់មានប្រាប់ថាម៉េច ស្ដីបន្ទោសគេទេ គេទៅបាត់ គាត់យកបង្គីកើបចោលហើយ ហើយបើសិនជាមុំផ្ទះខ្ញុំហ្នឹងជើងកបច្រើនណាស់។ មួយឆ្នាំៗ គ្រាន់តែឡានបុកមនុស្សហ៎ា ស្លាប់យ៉ាងហោចណាស់ក៏ពីរនាក់ដែរមួយឆ្នាំ ប៉ុន្ដែពេលឡានបុកម្ដងៗគាត់តែងតែឃាត់កូនហើយកុំឱ្យទៅមើល ថាខ្លាច កុំឱ្យគេធ្វើសាក្សីអីឱ្យ នាំពិបាកទេ។ ចឹងយើងនៅ

តែស្ងៀម កុំចង់ដឹងអី គាត់ថា...គេថាមិនចង់ឱ្យពាក់ព័ន្ធរឿងវែងឆ្ងាយហាំ។ រូចល្អមួយទៀត ត្រង់ថា ឧបមាថាក្នុងភូមិហ្នឹងវាមានឆ្កែវាឆ្កួតអីហាំ គាត់ស្រែកហៅគេហៅឯង ឱ្យជួយដេញវ៉ៃអាឆ្កែ ខ្លាចវាខាំក្មេងអីឆ្កួតហាំ តែគាត់នាំមុខគេទៅតែម៉ង មានដំបងឬស្សីមួយដេញតាម ទាល់តែវ៉ៃបាន បានគាត់ឈប់ដេញ។ ហើយនៅអណ្តូងទឹកហ្នឹងពេលគាត់ទៅងូតទឹកអី ជួនកាលគាត់រើសបាននាឡិកាដៃ ខ្សែក ខ្សែកយើងមាសហ្នឹងហាំ ព្រោះអ្នកខ្លះពាក់ទៅដល់ណុង គេដោះទុកហើយបានគេងូតទឹក ដល់គាត់រើសបានគាត់យកមកគាត់ថាបើពីណាគេដើររកបាត់អី បើពិតជាម្ចាស់គេមែន ហៅគេឱ្យមកយកហាំ។ ចឹងគាត់អត់ចង់បានរបស់គេទេ អាណុងវាទម្លាប់គាត់អាអីដែលត្រូវតែធ្វើល្អម៉ងហាំ។

ក៖ ហើយពួកគាត់ស្លូតទេអ៊ីន៎?

ខ៖ បាទ?

ក៖ ពួកគាត់ស្លូត?

ខ៖ ស្លូតណាស់!

ក៖ ជាមួយកូនអី ចៅអី?

ខ៖ កូនអី បើជាមួយខ្ញុំមិនដែលវ៉ៃខ្ញុំបានមួយរំពាត់ទេ។ ខ្ញុំដឹងពេលណាអត់សោះម៉ង (មានន័យថាធំដឹងក្តីឡើង មិនដែលគាត់វ៉ៃសោះ) មិនដែលវ៉ៃទេ។

ខ៖ ហើយចុះពេលដែលអ៊ុំនៅជាមួយពួកគាត់ដូចជា...ចង់និយាយថា បើសិនគិតពីខ្លួនអ៊ុំវិញ អ៊ុំបានរៀនសូត្រអីខ្លះពីពួកគាត់? អ្វីខ្លះដែលគាត់បានបង្រៀនដល់អ៊ុំ ឬក៏កូនផ្សេងៗទៀត?

ក៖ អូ៎! បង្រៀនមិញអាផ្នែកសីលធម៌រស់នៅ។

ខ៖ ចាស!

ក៖ គាត់មិនឱ្យយើងដូចថាចង់ដឹងរឿងគេ និយាយដើមគេ ហើយអាហ្នឹងជារឿងមួយដែលអ៊ុំត្រូវតែធ្វើតាមគម្រូហាំ ហើយជាពិសេសអារបៀបឈឺឆ្អើល(ចេះជួយ)អ្នកដ៏ទៃហាំ ឈឺឆ្អើលមិញ រឿងដែលឆ្កែសោះហាំ អ្នកខ្លះនៅនឹងភូមិស្រុកណុង ឆ្កែអីឆ្កែទៅ គេអង្គុយលើផ្ទះធ្វើមិនដឹង មើលយើងវិញ គេអត់ទេ តែគាត់ត្រូវតែដេញ ហើយនៅពេលដែលអណ្តូងហ្នឹង ខែប្រាំងឡើងវារីងហាំ ត្រូវរកមនុស្សស្តារ គាត់អ្នកចេញលុយ ចេញលុយឱ្យគេស្តារ។

ក៖ តែអណ្តូងហ្នឹង អណ្តូងរួម។

ខ៖ អណ្តូងសាធារណៈ។

ក៖ អណ្តូងសាធារណៈ។

ខ៖ អណ្តូងជីកដៃណា៎?

ក៖ ចាស!

ខ៖ អណ្តូងសាធារណៈ គាត់លក់ឥវ៉ាន់ចាបហួយហ្នឹងហា៎ ពេលទិញស្រាឱ្យលុយ ចុះម្តងឱ្យ២៥រៀល(លុយខ្មែរ) ២៥កាលណុង ធ្វើការមួយថ្ងៃទល់ល្ងាចហា៎ ២៥ហើយ ឱ្យស្រាផឹកទៀត ដូចថាធ្វើល្អឱ្យស្រាទៀត។

ក៖ ២៥រៀលជំនាន់ណុង ស្មើប៉ុន្មានទៅអ៊ុំមកដល់ឥឡូវ?

ខ៖ អ៎ូ កាលណុង១ជីកមាស អូ..១តម្លឹងមាសតែ៣ពាន់ទេណា៎។

ក៖ ៣០០រៀលលុយខ្មែរ?

ខ៖ ៣០០រៀលលុយខ្មែរ រួច២៥ស្មើប៉ុន្មានទៅ?

ក៖ (សើច)

ខ៖ ៣០០ មួយជី។

ក៖ ចាស!

ខ៖ បើចឹង២៥ថាមួយហ៊ុនចុះ ឱ្យវាស្មើនឹង៣០។

ក៖ ចាស!

ក៖ មួយហ៊ុន! អ្នកហ្នឹងផឹកទឹកហ្នឹងដែរ រួចដែលគាត់ជួលមក ដូចវាថាអត់ទំនងហា៎ ព្រោះយើងអ្នកជីកដែរ យើងចូលរួមស្តារទាំងអស់គ្នា ប៉ុន្តែគាត់អត់គិតចឹងទេ គាត់ឱ្យលុយ។ គាត់ឱ្យលុយអ្នកទៅធ្វើការហ្នឹង។

ក៖ ហើយចឹងអ៊ុំនិយាយពីដើមមិញ ពួកគាត់លក់ឥវ៉ាន់ចាបហួយអ៊ុំន៎?

ខ៖ ហ្នឹងហើយឪពុកខ្ញុំលក់ឥវ៉ាន់ចាបហួយ។

ក៖ ចុះម្តាយអ៊ុំ?

ខ៖ ហា?

ក៖ ចុះម្ដាយអ៊ុំគាត់លក់ឥវ៉ាន់ចាបហួយជាមួយគ្នាដែរ?

ខ៖ ហ៊ឹម! លក់ជាមួយគ្នាណុង។

ក៖ លក់ជាមួយគ្នាអ៊ុំន៎! ដូចជាពួកគាត់អី អ៊ុំដែលធ្លាប់ឮដំណាលពីរឿងគាត់អីពីក្មេងអីមក ដែលមានទេអ៊ុំ?

ខ៖ អូ៎ ដែល! គាត់និយាយថានៅស្រុកចិនពីសង្គ្រាមលោកលើកទី២ហាំ គេត្រូវការជ្រើសរើសកងទ័ព ដូចសម័យទាហាន លន់ នល់ ចឹងហាំ។ ចឹងគាត់រត់ពីស្រុកចិនមកស្រុកខ្មែរហាំ។

ក៖ អញ្ចឹងឪពុកអ៊ុំចិន?

ខ៖ ចិនទេ!

ក៖ មកពីៗ...

ខ៖ ប៉េកាំង!

ក៖ ប៉េកាំងមកម៉ង អ៊ុំន៎?

ខ៖ ហ្នឹងហើយ!

ក៖ អូ៎!

ខ៖ គាត់អត់ចេះនៅទេ ហើយកាលធ្វើដំណើរមក ឆ្លងកាត់វៀតណាមនៀក ហើយពងទាមួយហូបមួយខែ ពងទាយើងហ្នឹងហាំ។

ក៖ ពងទាប្រៃហ្នឹងហាំអ៊ុំ?

ខ៖ អត់ពងទាប្រៃទេ ពងទាសាបហាំ។

ក៖ ហូបម៉េចទៅបានមួយខែ?

ខ៖ គាត់ដាក់ទឹកត្រី ទឹកអី ធ្វើម៉េចឱ្យ គាត់យកចង្កឹះទៅជ្រលក់ហើយចុចចឹងទៅលិតៗហាំ។

ក៖ ហ៊ឹម!

ខ៖ ហើយទម្លាប់កូនទាំងអស់ ចេះហូបប្រែទាំងអស់ ដោយសារអី? ដោយសារហូបសាបវាអស់ច្រើន ចឹងត្រូវហូបប្រៃ រួចចឹងអ្នកហូបប្រៃហ្នឹង ច្រើនតែពួកកុម្មុនីស។ ពួកកុម្មុនីសហ្នឹងវា ពេលដែលហូបតិច ហូបម៉េចកើត។ ហូបតិចវាអត់គ្រាន់ គាត់ថាខ្លាញ់ជ្រូកឆាជាមួយក្រួសយើងហ្នឹងហាំ លាងឱ្យស្អាតទៅ ដាក់ខ្ទះឆាអំបិល ដាក់ស្អីៗចឹងទៅ ដល់ហូបយើងយកវាមកជញ្ជក់ៗមកពិបាកណាស់ណាំ ហើយគាត់មកមុនដំបូងហ្នឹង អត់មានលុយទេ គាត់ការងារអីក៏ធ្វើដែរ ធ្លាប់ច្រូតស្មៅលក់ឱ្យគេ ស្មៅ ស្មៅគោស្មៅក្របីរាល់ថ្ងៃហ្នឹង ដល់ក្រោយមកគេបង្កើតសមាគមចិនសមាគមចិនហ្នឹងនៅកំពង់ចាម ឈ្មោះ ប៉ុល អាន ទាហាន។ ប៉ុល អានហ្នឹងអ្នកមានពីដើមហាំគាត់មានឡានរត់ឈ្នួល ប៉ុល អានហ្នឹងគេតែងតាំងដូចជាចៅហ្វាយខេត្តចឹង ដូចមានអំណាចហាំ ដល់ចឹងពួកហ្នឹងខ្វះលុយរកស៊ីអី គេតែងមានសមាគមគេ។ សមាគមគេ គេជួយលុយជួយកាក់។

ក៖ អូខេ! ហើយដល់ពេលគាត់មកពីចិនមក មកដំបូងមកមិនអត់ចេះខ្មែរទេអ៊ុំ ពេលចឹងម៉េចទៅ? ទៅរៀនខ្មែរអី ម៉េចបានចាប់ផ្តើមចេះ?

ខ៖ មុនដំបូងៗអត់ចេះទេ តែក្រោយមកក៏នៅអត់ចេះ ចេះតិចតួច ពិបាកណាស់ ពិបាករស់នៅណាស់។

ក៖ ចាស! ហើយចុះម្តាយអ៊ុំគាត់ជនជាតិខ្មែរ?

ខ៖ គាត់កើតនៅស្រុកហ្នឹងហ្នំ។ គាត់ណុងឪពុកយួន កូនអឺ...ម្តាយយួនកូនខ្មែរ អ៊ំ...ឪពុកចិនម្តាយយួន។

ក៖ អ៊ូ! អញ្ចឹងគាត់កូនចិន កាត់វៀតណាម។

ខ៖ កាត់វៀតណាម ប៉ុនប្រហែលកូនហ្នឹងច្រើនតំណហើយ ខ្ញុំអត់ដឹងទេណាំ។

ក៖ ចាស!

ខ៖ ប៉ុនម៉ា(យាយ)ខ្ញុំ គាត់រៀនធម៌ខ្មែរ ខ្មែរគាត់រៀនដល់សីល១០ហាំ ចេះសូត្រធម៌ហ្នឹងសីល១០ហាំ។ ចឹងគាត់ចេះច្រើនណាស់។

ក៖ ខាងហ្នឹងខាងម្តាយ ក៏ខាងឪពុក?

ខ៖ ខាងយាយមិញ ម៉ានេះ។

ក៖ ចាស! ម៉ាហ្នឹងខាងម្តាយអ៊ុំហ្អេ?

ខ៖ នេ់ម្ដាយស្អី...អូ ត្រូវហើយម្ដាយ មិនមែនម្ដាយអ៊ុំទេ យាយ...

ក៖ ប៉ុនយាយរបស់អ៊ុំ ប៉ុនខាងម្ដាយហ្អេ៎?

ខ៖ ហ្នឹងហើយខាងម្ដាយ! ព្រោះកាលណោះ ខាងណោះមកពីស្រុកចិនមក ប៉ុនយាយមិននៅជាមួយម្ដាយយើង។ ចឹងខាងម្ដាយ!

ក៖ ចុះអូ...ចឹងអ៊ុំស្គាល់ជីដូនខាងម្ដាយ។ ចុះជីតា?

ខ៖ ជីតាយើងហ៎?

ក៖ ចាស! ប៉ុនខាងម្ដាយរបស់អ៊ុំ? ឪពុករបស់ម្ដាយអ៊ុំ?

ខ៖ និយាយអំពីម៉ា ចុះកុង?

ក៖ អូ៎! ឪពុករបស់ម្ដាយ តាមិញមកពីស្រុកចិនមិញហ៎។ ឈ្មោះតាហួត។ តាហួតហ្នឹងមកពីស្រុកចិនដែរ ហើយមានប្រពន្ធ ប្រពន្ធមិនត្រូវជាម្ដាយយើង? ត្រូវម៉ាយើង ប៉ុនមិនត្រូវជាម្ដាយរបស់ម្ដាយយើង។

ខ៖ ម៉េចដែរ? ស្ដាប់ទាន់ទេចឹង? (យល់ឬអត់?)

ក៖ ទាន់ៗ! ហើយចុះខាងឪពុករបស់អ៊ុំ ជីដូនជីតាខាងឪពុក?

ខ៖ អូ៎! អត់ស្គាល់ទេ នៅស្រុកចិនហ៎។

ក៖ ដោយសារអ៊ុំអត់ដែលឮគាត់ជំណាលពីឪពុកម្ដាយគាត់អីអត់ដែលទេអ៊ុំន៎?

ខ៖ អត់ទេ! ប្រាប់ទៅក៏យើងមិនដឹងដែរ ព្រោះវានៅឆ្ងាយចែកទ្វីបគ្នាទៅហើយ មិនអាចដឹងទេ។

ក៖ ហើយចុះអឺ...អូ៎! ចឹងដោយសារឪពុកអ៊ុំ គាត់ចិន ហើយម្ដាយអ៊ុំ ចិនកាត់វៀតណាម ចុះពេលអ៊ុំកើតមកនៅក្នុងក្រុមគ្រួសារដែលរៀនចិន ឬក៏និយាយចិនអីមានទេ? នៅពីក្មេងមក ក៏អត់ទេ?

ខ៖ ពីក្មេងមក អក្សរចិនអត់ដែលបានរៀនទេ បើអាភាសាចិនហ្នឹង ចេះតិចតួចព្រោះអ៊ុំអត់សូវចំណូលចិត្តអារឿងនិយាយចិនហ្នឹង តាំងពីកូនឡើង អត់ស្រឡាញ់ម៉ង អត់ចូលចិត្តទេ មិនដឹងយ៉ាងម៉ាច មើលទៅវាភ្លាវហ៎។

ក៖ ចឹងចេះតិចតួចហ្នឹង ចេះមកពីឪពុកឬក៏ម៉េចដែរ?

ខ៖ អើនៅជាមួយគ្នាហ្នឹងហ្អា។

ក៖ ព្រោះគាត់ចិនអ៊ុំន៎។

ខ៖ អើ! នៅជាមួយគ្នាយ៉ាងហោចក៏វាចេះខ្លះដែរ ចៀសមិនរួចពីរឿងចេះទេ។

ក៖ ចាស!

ខ៖រួចដែលអត់ចេះហ្នឹង ខ្ញុំរស់នៅហ្នឹង ចិនក្នុងភូមិហ្នឹងវាមានប្រហែលមិនដល់១០គ្រួសារផង។ យើងទៅរស់នៅដូចជនជាតិភាគតិចចឹងហា៎។

ក៖ ចាស!

ខ៖ ដូចយូនមកនៅភូមិខ្មែរចឹងហា៎។ អញ្ចឹងយើងរស់នៅហ្នឹងក៏គ្រានតែ វាចេះអរិយធម៌ខ្មែរវាច្រើនជាងហា៎ ចឹងយើងអត់សូវចេះចិនទេ ព្រោះយើងនិយាយអី យើងនិយាយតែជាមួយខ្មែរហ្នឹង។ ខ្មែរពួកម៉ាកមិត្តភក្តិយើង ពេលទៅរៀនអី ពួកហ្នឹងហា៎។

ក៖ ហើយដូចជាអ៊ុំមានសាច់ញាតិណាអីដែលគាត់ទៅរស់នៅក្រៅប្រទេសអី មានទេអ៊ុំ?

ខ៖ សាច់ញាតិ មានក្មួយ មានជីដូនមួយ មានជីទួតមួយ ក្មួយបង្កើតមាន២នាក់ នៅអូស្ត្រាលី ប៉ុនអាមួយវាមកខ្មែរវិញហើយ ហើយអាក្មួយជីទួតមួយនៅអូស្ត្រាលីដែរ ពីរបីនាក់ហ៎ា ប៉ុនខាងជីទួតមួយទេណា៎។

ក៖ ចឹងពួកគាត់ដែលទៅនៅក្រៅស្រុកហ្នឹង គាត់នៅអូស្ត្រាលីទាំងអស់។

ខ៖ អូស្ត្រាលី ហើយមួយទៀតជីដូនមួយ នៅកាណាដា ស្រី។ កាលដាច់អាឆ្នាំ៧៩ហ្នឹង គេភៀសខ្លួនទៅណុង កាណាដា។

ក៖ អូខេ! ហើយចឹងចង់សួរទាក់ទងការរៀបការរបស់អ៊ុំវិញ ជីវិតរៀបអាពាហ៍ពិពាហ៍?

ខ៖ អ៊ូ! រៀបការនៅឆ្នាំ៧៣ ខែ៩ ឆ្នាំ៧៣ សម័យ លន់ នល់។

ក៖ អ៎!

ខ៖ នៅហាង! នៅហាងកាលណុងនៅម្តុំខាងលិចព្រហ្មទណ្ឌនេះ ឈ្មោះអី ហាងអី ភ្លេចបាត់ហើយ យូរហើយ។

ក៖ នៅកំពង់ចាមអ៊ុំន៎។

ខ៖ កំពង់ចាមយើយ! អ្វ! សៀម មៅ ចឹញ ហាងគេ ហាងធំគេណាំ ដូចភ្នំប្រុសភ្នំស្រីចឹងណាំ។

ក៖ ហើយអ៊ុំពេលរៀបការហ្នឹង អ៊ុំអាយុប៉ុន្មាន ហើយអ៊ុំស្រីអាយុប៉ុន្មាន។

## វីដេអូទី២

ក៖ ចឹងសុំសួរម្តងទៀត អ៊ុំរៀបការនៅអាយុប៉ុន្មានអ៊ុំ?

ខ៖ អាយុ២៤ ការនៅឆ្នាំ៧៣ សម័យសាធារណរដ្ឋ លន់ នល់។

ក៖ ហើយអ៊ុំស្រីម្ដែប៉ុន្មានអ៊ុំ?

ខ៖ ២៣!

ក៖ ២៣! ហើយអឺ...

ខ៖ និយាយបង្ហើរ អត់សួរ ប៉ុនប្រាប់ដែរ។ នេ៎! ខ្ញុំការបានតែ១៨ថ្ងៃទេ បែកគ្នាដោយសង្គ្រាម សង្គ្រាមចឹងទៅ ប៉ុល ពត ចូលមក ខ្ញុំជញ្ជូនក្មួយមក មកក្នុងផ្សារ មុខផ្សារកំពង់ចាមយើងហ្នឹង រួចទៅប្រពន្ធនៅកន្លែងស្អាត នៅផ្ទះបងប្អូន ហើយយើងអាតតែយកក្មួយមក ហើយដល់ ប៉ុល ពត វាផ្លោងខ្លាំងពេក គេចេញទៅក្រៅនំ។ ឪពុកម្ដាយគេចេញតាមព្រែកច័ន្ទ ចេញទៅ ទៅ រហូតចម្ការលើហាំ។ វង់ពីហ្នឹងទៅ ទៅចេញចម្ការលើ ចម្ការលើនៅចំផ្ទះបងខ្ញុំ បងប្រុសខ្ញុំហាំ អត់ស្គាល់ទេ ប៉ុនអ្នកដំណើរ ពេលទៅទៅ សួរនាំ សួរៗទៅចំបងប្អូនយើង ដែលស្នាក់នៅណុង អស់ជិតមួយខែ បានពួកខ្មែរក្រហមណុង បញ្ជូនយើងទៅមុខទៀត អត់ឱ្យនៅហ្នឹងទេ វាខ្លាច ពួកយើងរត់មកវិញហាំ។

ក៖ ចាស!

ខ៖ ហើយក្រោយមក៣ខែ ក្រោយមក៣ខែ ខ្ញុំចេញ ចេញតាមក្រោយ កាលណុងឱ្យទាហាន អស់៧ម៉ឺន ធ្វើការរោងចក្រយើង ចេញទៅតាមផ្លា តាមវិហារធំ រួចដល់វិហារធំ ជិះទូកពួកអង្គការ វាបញ្ជូនទៅពាមជីកងណោះ។ ភូមិពាមជីកង ដេកមួយយប់ ជាមួយអ្នកទោស អ្នកអីណុង អ្នកទោសសុទ្ធតែជាប់ច្រវ៉ាក់ ប៉ុនយើងគ្រាន់តែដេកទេណាំ ហើយព្រលឹមឡើងមកបានជូនវា ទៅជិះកង់ ឌុបវាទៅ ទៅដល់បុសខ្នុរ ម៉ោងប្រហែល៧យប់ ៧យប់ទៅបានទៅដល់ផ្ទះបង

យើង។ ទៅដល់ផ្ទះបងយើងទៅ បានប្រហែលកន្លះខែទៀត បានយើងសុំសំបុត្រទៅជួបប្រពន្ធហាំ។

ក៖ អញ្ចឹងអ៊ុំស្រី គាត់ឈ្មោះអីដែរ ប្រពន្ធអ៊ុំ?

ខ៖ ឈ្មោះ ប៉ាវ ស៊ីនន!

ក៖ ប៉ាវ ស៊ីនន! ហើយគាត់...ដូចជាពេលដែលអ៊ុំជួបជាមួយអ៊ុំស្រីហ្នឹង អ៊ុំស្គាល់គាត់តាមរបៀបណា? មុនរៀបការហ្នឹងណាំ?

ខ៖ អ៊ូ! បងជីដូនមួយខ្ញុំ គាត់ធ្លាប់ទៅទិញ ទិញត្រកួនទិញត្រាវអីហ្នឹង យកមកឱ្យជ្រូកស៊ី ទិញត្រាវរបស់ប្រពន្ធខ្ញុំហ្នឹងណាំ ហើយចឹងគេស្គាល់។ គេស្គាល់ទៅ គេស្រឡាញ់ហាំ គេស្រឡាញ់ប្រាប់ខ្ញុំឱ្យទៅស្តីដណ្តឹងអីចឹងហាំ។

ក៖ ចាស!

ខ៖ ហើយអង្កាលណុង យើងគ្មានចិត្តស្រឡាញ់អីទេ គ្រាន់តែធម្មតាៗ វាមិនស្រឡាញ់អីទេ គិតអញ្ចឹងហាំ។

ក៖ ចាស!

ខ៖ រួចទៅដល់បានរៀបការហ្នឹង បានប៉ុន្មានតែ៣ខែមិញហ្នឹង បែកគ្នា៣ខែ មិនដឹងស្គាល់មុខអាមិចផង យើងការតែ១៨ថ្ងៃហើយបែករហូតដល់៣ខែ អត់ស្គាល់ ភ្លេចមុខបាត់។

ក៖ ព្រោះអីនៅជាមួយគ្នាបានតែ១៨ថ្ងៃ។

ខ៖ ១៨ថ្ងៃ...

ក៖ ហើយពីមុនហ្នឹង ក៏អត់សូវស្គាល់ទៀត។

ខ៖ អត់ទេ! អត់ស្គាល់ផង។ រួចទៅ ទៅដល់ជំនាន់ ប៉ុល ពតហ្នឹង រួចអាហ្នឹងនិយាយវែងឆ្ងាយមិនដឹងកន្លះផងនៀក។ អាហ្នឹងជីវិតធំហើយណាំ បើជីវិតអាកាលពីតូចក៏មានរឿងច្រើនទៀត ប៉ុនអាហ្នឹងនិយាយកាត់ៗអស់ហើយណាំ ខ្ជិលឱ្យរៀបរាប់រឿងលម្អិតពេក។

ក៖ អូខេ! ឥឡូវប្រហែលខ្ញុំសួរ សំណួរមួយទៀតបញ្ចប់សិនទាក់ទងនឹងការរៀបការរបស់អ៊ុំហ្នឹង ពេលដែលអ៊ុំការជាមួយអ៊ុំស្រីហ្នឹង មានជូនជាបណ្តាការទេអ៊ុំ?

ខ៖ មានតើ! ការណុងគេយកតិចទេ មិនច្រើនប៉ុន្មានទេ។ ដូចគេគិតថារៀបការអស់ប៉ុន្មានចឹងទៅ យើងចេញទៅណា៎ ចែកគ្នាចេញទៅណា៎ គេមិនបង្គាប់អីទេ។

ក៖ ហើយចឹង អ៊ុំជូនអ៊ុំស្រីប៉ុន្មានទៅ?

ខ៖ កាលណុងមិនចាំទេ ប្រហែលជាពីរបីតម្លឹងអីប៉ុណ្ណឹង។ ជូនហ្នឹង មិនជូនជាលុយទេ ជូន...

ក៖ មាស!

ខ៖ យើងអាពិធីហ្នឹង យើងចំណាយហា៎។

ក៖ អូខេ!

ខ៖ យើងចំណាយប៉ុន្មាន យើងចេញទៅណា។

ក៖ ចាស!

ខ៖ មិនមែនយើងឱ្យលុយទាំងដុលទៅទេ។

ក៖ ចាស! យល់ហើយអ៊ុំ! ហើយអ៊ុំចេះអាន និង សរសេរភាសាខ្មែរអ៊ុំន៎?

ខ៖ អូ! ខ្ញុំធ្វើគ្រូទៀតន៎។

ក៖ អូខេ! ហើយចុះភាសាបរទេស? អ៊ុំចេះភាសាអីផ្សេង ក្រៅពីភាសាខ្មែរហ៎?

ខ៖ ក្រៅពីភាសាខ្មែរ ចេះបារាំងខ្លះ ចេះអង់គ្លេសតិចតួច។

ក៖ បារាំង អ៊ុំរៀនជំនាន់...?

ខ៖ ជំនាន់ សម័យស្តេចសីហនុ។

ក៖ រៀនបានប៉ុន្មានដែរអ៊ុំ?

ខ៖ រៀនអង្កាលណុង បានតែប៉ុន្មានឆ្នាំ ហើយសង្គ្រាមហ្នឹង។

ក៖ ក៏ឈប់រៀនទៅ។ អញ្ចឹងប្រហែលជា មិញអ៊ុំនិយាយទាក់ទងពីជីវិតរបស់អ៊ុំ ចឹងអ៊ុំប្រហែលជាអាចប្រាប់ខ្ញុំខ្លះៗពីជីវិតរបស់អ៊ុំណា៎ ពេលដែលអ៊ុំធំឡើងចឹង? ដូចជាខ្សែជីវិតរបស់អ៊ុំ តាំងពីក្មេងរហូតដល់អ៊ុំធំឡើងអី?

ខ៖ អ៊ូ! ឥឡូវនិយាយពីកាលនៅតូចហ៎ា តូចមិនទាន់បានរៀនទេ ហើយខ្ញុំឈឺអើយឈឺ ឈឺច្រើនណាស់ ឈឺខ្លាំង មើលអត់ចង់ជាទេ គេស្មានតែស្លាប់ហើយ ដល់ចឹងទៅរកគ្រូខ្មែរ វាទ័លមិនដឹងទៅរកអី មានតែទៅរកគ្រូខ្មែរ។ ពីដើមគេច្រើនជឿលើអាគមអូមអាមហ្នឹងហ៎ា។

ក៖ ចាស!

ខ៖ ប៉ុន្តែដល់ចុងបញ្ចប់ គេធ្វើពិធីមួយ ពិធីសែនប្រេន ពិធីសែនប្រេនហ្នឹងបែបព្រហ្មសាសនា គេយកខ្ញុំ អាហ្នឹងម្ដាយខ្ញុំនិយាយប្រាប់ទេណា៎ យកខ្ញុំហ្នឹងទៅនឹងផ្ដៀង យើងដឹងអាយុប៉ុន្មានឈឺហ្នឹង ដាក់នឹងផ្ដៀង ហើយឱ្យព្រះសង្ឃហ្នឹងគេថាបិណ្ឌបាតហ៎ា បិណ្ឌបាតហ្នឹងគឺថាយករើសមកចិញ្ចឹម។

ក៖ អ៊ូ!

ខ៖ រើសមកចិញ្ចឹមហ៎ា!

ក៖ ចាស!

ខ៖ ហើយរកម្ដាយដោះមួយទេ ម៉ែដោះហ្នឹង ម្ដាយធម៌យើងហ៎ា ដល់ម្ដាយធម៌ហ្នឹង ហើយយកយើងទៅដាក់នៅផ្លូវបំបែកជាបួន។

ក៖ យកអ៊ុំហ្នឹង?

ខ៖ ក្មេង យើង អ៊ុំហ្នឹងនៅពីតូច នៅអាយុប៉ុន្មានឆ្នាំ ពេលឈឺដាក់នៅហ្នឹងទៅ ឱ្យលោកទៅសុំគេហៅបិណ្ឌបាត ឱ្យលោកសុំយកហ៎ា។ យកមកហើយ យកទៅឱ្យអ៊ីមួយទៀតគាត់អ្នកធ្វើជាម្ដាយចិញ្ចឹម មេដោះហ៎ា។ ប្រវត្តិហ្នឹងពិបាកណាស់ណា រួចតាំងពីណុងមក ខ្ញុំលេសឈឺរហូត។

ក៖ ហើយចឹងអ៊ុំទៅនៅជាមួយគាត់រហូតដល់អាយុប៉ុន្មាន?

ខ៖ អត់ទេ!

ក៖ ក៏ម៉េច?

ខ៖ អត់នៅជាមួយទេ! គ្រាន់តែម្ដាយដោះ គេចាត់ទុកយើងជាម្ដាយទៅណា៎។

ក៖ ចាស!

ខ៖ គេចាត់ទុកជាម្ដាយ ប៉ុនមិនមែនយើងទៅប៉ៅដោះគាត់រាល់ថ្ងៃទេ។ គ្រាន់តែថាប៉ៅម្ដាយក៏គេហៅថាម្ដាយយើងដែរចឹងហ៎ា។

កៈ អូ! យល់អ៊ុំ!

ខៈ រួចទៅ តាំងពីណុងមក យើងបានជា។ ជាហើយ ខ្ញុំនិយាយកាត់តិចទៅ ខ្ញុំរៀន រៀនសិស្ស សាលាហ្នឹង នៅអាយុប្រហែល១៣ឆ្នាំទេយ៉ាង ខ្ញុំធ្លាក់អណ្តូង។ អណ្តូងជម្រៅ១១ម៉ែត្រ ទឹកពេញហាំ ទឹកជិតដល់លើ ប្រហែលនៅមួយម៉ែត្រទៀតទៅដល់លើ។

កៈ អ៊ុំអាយុ១៣ឆ្នាំ?

ខៈ ១៣ឆ្នាំ! តែខ្ញុំអាហ្នឹងក្មេងខ្ជិលហាំ ទៅដងទឹក អត់យកយោងទៅទេ យកដងវែង ហើយនិងអាខ្សែថាំងហ្នឹងដាក់បោត...

កៈ ជ្រលក់ចូល!

ខៈ ជ្រលក់មុជទៅលើក រាល់ដងវាអត់អីទេណាំ ចេះតែចឹងរាល់ថ្ងៃ ដងតែចឹងមក មកផ្ទះរាល់ថ្ងៃ។ ស្រាប់តែថ្ងៃណុងវាចៃដន្យអី លើកមកវារអិលជើងទៅ។ វាធ្ងន់ពេក វារអិលទៅ ធ្លាក់ទាំងប៉ោត ទាំងមនុស្ស ទាំងខ្សែថាំង ដងវែក រួចទៅលិចផ្លឹប ផ្លឹបទៅយើងអត់ចេះហែល។ យើងអត់ចេះហែល មុជជ្រៅទៅចេះតែនឹកឃើញ ហើយ! ម្តាយអត់ដឹង ប្រហែលជាស្លាប់ហើយ អត់រស់ទេ។ នឹកក្នុងខ្លួនយើងចឹងហាំ?

កៈ ចាស!

ខៈ ក្រោយពីនឹកទៅ យើងចេះតែលិចត្រឹមនេះទៅ ក្រោយពីលឹបទៅ យើងនឹកឃើញប្រផ្នូលមិនល្អហាំ សួរគេថាតើអាហែលទឹកហ្នឹង គេហែលរបៀបម៉េច? ហែលឈរចឹងហាំ? គេប្រាប់ថាអាហ្នឹងយើងដូចជិះកង់អីចឹងទៅជើងហាំ ហើយដៃយើងទទះចឹង។

កៈ សួរ សួរគេម៉េចអ៊ុំ? ពេលណុងអ៊ុំកំពុងតែលង់ទឹក?

ខៈ សួរណុង សួរមុនធ្លាក់ហ្នឹង សួរគេ...

កៈ នឹកឃើញអ៊ុំហ្អេ?

ខៈ សួរគេ សួរពួកម៉ាក!

កៈ ប៉ុនអ៊ុំនឹកឃើញ ពេលអ៊ុំកំពុងលង់ទឹកហ្នឹង?

ខៈ នឹកឃើញ!

កៈ អូ!

ខ៖ នឹកឃើញថា អាហែលឈរហ្នឹង ជើងគេធាក់ដូចធាក់កង់ ហើយដៃគេទទះ នឹកឃើញគេប្រាប់ចឹង ហើយធ្វើតាមគេ។ ធ្វើតាមគេ ស្រាប់តែវាអណ្តែតមកវិញ អណ្តែតប្រហែលជាត្រឹមនៀក។ យើងឃើញថាភ្លឺតែមួយភ្លែតទេ ហើយក៏លិចទៅវិញ លិចទៅវិញលើកទីពីរហ្នឹង យើងធាក់កង់ អាធាក់ជើងខ្វៃងៗ ហើយដៃទទះ ឱ្យប្រឹងលើសមុនបន្តិច បានដល់ត្រឹមនេះ ឃើញតែមួយភ្លែតត្រឹមហ្នឹង យើងស្រវ៉ាតោងភ្នោះអណ្តូង អាភ្នោះអណ្តូងហ្នឹង វាធ្វើភ្នោះពីជើងហា៎។ ថ្នោះពីឈើ គេវ៉ៃដូចធ្វើទ្រូងជ្រូកចឹងហា៎។ យើងស្រវ៉ាតោង តោងអត់ជាប់ លិចទៅវិញទៀត។ លិចទៅទៀត អាហ្នឹងអស់ផ្លូវហើយណា៎ម្តងហ្នឹង។ យើងប្រឹងម្តងទៀត ប្រឹងហ្នឹងចុងក្រោយ បើឡើងមិនរួចទេ គឺស្លាប់ហើយ ស្រាប់ដល់ម្តងទៀត វាអណ្តែតប្រហែលដល់ត្រឹមទ្រូង ម៉ាយើងទទះខ្លាំង យើងប្រឹងអស់ហា៎ ស្រាប់មកភ្លុត វាអណ្តែងផុសមកណា៎ ហើយយើងតោងភ្នោះអណ្តូងជាប់ ហើយយើងដើរឡើងមក យើងដើរឡើងមក ស្រាប់តែឃើញមនុស្សច្រើនណា៎រត់ទៅមើលយើងហា៎ ជុំវិញខ្លួនយើងប្រហែលជាចង់មួយរយនាក់ ទៅមើលយើងថាធ្លាក់អណ្តូងចឹងហា៎។ ហើយក្រោយមក មួយឆ្នាំពីរក្រោយមកមានក្មេងធ្លាក់ងាប់អស់ម្នាក់ទៀត អណ្តូងដដែរណុង ហើយអាឡានបុកគ្នាណុង ធ្លាក់អាព្រូឡានចូលក្នុងណុងដែរ ប៉ុន្តែអាឡានណុងវាបុកភ្នោះអណ្តូងបែកទៅ វាធ្លាក់ចូលចឹង ហើយមនុស្សធ្លាក់ទៅ គេតោងហា៎ តោងអាឈើអណ្តែងហ្នឹង គេនាំគ្នារត់ទៅជួយយកចេញមក។

ក៖ ចឹងមានតែអណ្តូងហ្នឹងនៅក្បែរផ្លូវអ៊ុំ? ក៏យ៉ាងម៉េច? បើឡានបុកគ្នា...

ខ៖ ប្រហែលជា៥ម៉ែត្រពីផ្លូវ!

ក៖ បើឡានបុកគ្នាធ្លាក់ចូលអណ្តូង...អូ! ជាប់ផ្លូវ...

ខ៖ វាមិនមែនបុកលើផ្លូវអញ្ចេះ វាកៀគ្នាម៉េច វាលេងផ្លូវកាត់ចុះស្រែ

ក៖ ហើយក៏តម្រង់ទៅអណ្តូង?

ខ៖ ទៅចំ ចូលអណ្តូងណុង បរឡាន អាឡានដឹកឈើ ឡានមានកន្ទុយវែងៗហា៎។ បុករះដាច់ភ្នោះអណ្តូងទៅ ទៅធ្លាក់ចំអណ្តូង។ រួចទៅស្រង់ឡើងមក ក្រោយមកធ្លាក់ក្មេងមួយទៀតងាប់។ ប្រវត្តិ ប្រវត្តិដល់ហើយ មុនចូលអាសម័យថាមានជីវិតដល់ប៉ុណ្ណឹងហា៎។

ក៖ ចាស!

ខ៖ ច្រើនណាស់ សាច់រឿងមិញហ្នឹង។ ហាំឥឡូវនិយាយពីរឿងដល់អាសម័យប៉ុលពត។ អូ! នៅទេ មិនទាន់ដល់សម័យប៉ុលពតទេ។ ហើយនិយាយមិញវាឆ្លងកាត់ដល់រៀបការហើយ មុនរៀបការខ្ញុំអាយុប្រហែលជា២០ឆ្នាំ មានរត់ប្រហារមួយ ដោយលន់នល់ហាំ?

ក៖ ហ្នឹងចិតប៉ុន្មានអ៊ុំ?

ខ៖ ចិតគត់ ១៨មិនា ឆ្នាំ១៩៧០។ ចាំទាំងថ្ងៃខែទៀត ទម្លាក់សម្តេចសីហនុហ្នឹង ហើយបាតុកម្មពីអ្នកស្រុកមកច្រើនហាំ ហើយខ្ញុំពេលណុងខ្ញុំទៅនៅចម្ការលើងនោះ ហ្នឹងហើយ ទៅនៅជាមួយបងនៅចម្ការលើ រួចអ្នកស្រុកណុងវាយសម្លាប់គ្រូបង្រៀនមួយ គ្រូបង្រៀនហ្នឹងយកក្រដាសរូបសម្តេចហ្នឹងទៅកិតអាចម៍។

ក៖ អ៊ូ! អញ្ចឹងគេខឹងអ៊ុំហាំ?

ខ៖ គេខឹងគេ គេស្រឡាញ់សម្តេចហើយយើងទៅធ្វើចឹង គេវាយងាប់នៅស្វាយទៀប រួចយកមកដល់បុសខ្នុរ គេដឹកមកហាំ។ រួចយកមកចងបង្គោលខ្សែភ្លើង បង្គោលខ្សែភ្លើងពីដើម វាឈើហាំ គេដាក់ឈើបង្គោលចឹង យកចង។ ចងណុងទៅ ថ្ងៃណុង តាំងពីព្រលឹម ឡានទាំងអស់ត្រូវបានបាតករយកទៅជិះទៅភ្នំពេញ រួចអ៊ុំគេច អត់ហ៊ានទៅទេណា។ អ្នកដឹងថាមិនហ្នឹងសុទ្ធតែរឿងហើយ ប៉ុន្តែយើងដឹងថា បើយើងទៅនាំគ្រោះថ្នាក់ទេ យើងគេចនៅផ្ទះ ស្រាប់ឮសម្លេងមនុស្សផ្អើរឈូឆរ ដូចមានអាសន្នចឹងហាំ រត់ពីផ្សារបុសខ្នុរចុះមកភូមិយើងហើយ។ រួចឮព័ត៌មានអត់ដឹងថាវាកើតអីទេ ម្តងឮថាឆ្កែឆ្កួត ម្តងឮថាមនុស្សឆ្កួត ស្រាប់ដល់វាស្ងាត់ទៅវិញរឿងអាអ្នកស្រវឹងស្រា ទៅគប់អាខ្មោចគេចងព្យួរហ្នឹងហាំ គប់ទៅ វាដាច់ខ្សែធ្លាក់មក អាអ្នកស្រវឹងវាភ័យវារត់ រួចអាមួយឃើញរត់ វារត់តគ្នាមកផ្អើលមកដល់យើង។ កាលណុងវាល្អមើលដែរណាំ។

ក៖ ហ្នឹងនៅបុសខ្នុរអ៊ុំន់?

ខ៖ បុសខ្នុរ! រួចផុតពីសង្គ្រាមហ្នឹងទៅ ទទួលពួកវៀកកុង ហើយនិងខ្មែរក្រហមហ្នឹង វាត្រូវវាយវាបង្កើតទ័ពរណសេ សម្តេចសីហនុអ្នកបង្កើតហាំ កាលពណុងទម្លាក់រួចទៅ សម្តេចទៅប៉េកាំងស្រែកតាមវ៉ាត់យូ(វិទ្យុ)ប៉េកាំងមកថាឱ្យកូនចៅចូលតស៊ូអីណាអីណី រួចយើងស្រឡាញ់គាត់ចេះតែទៅហើយ អាយុ...ជីដូនមួយខ្ញុំអាយុប៉ុនគ្នាហ្នឹង ស្លាប់អស់ ស្លាប់ដោយសារតែរឿងតស៊ូហ្នឹងហាំ ដោយសារឡើងទៅច្បាំង ច្បាំងគ្រាប់កាំភ្លើង បើមិនត្រូវគេ ត្រូវយើង។

ក៖ ចាស! ទៅហ្នឹង គេរើសទៅ ក៏ស្ម័គ្រចិត្តទៅខ្លួនយើង។

ខ៖ ស្ម័គ្រចិត្ត អត់រើសទេកាលណុងហ៎។ រួចផុតពីហ្នឹងទៅ ដល់សង្គ្រាមឆ្នាំ១៩៧៣ អ៊ូ! អត់ទាន់ទេរំលងបន្តិច កាលរត់ប្រហាររួច នៅសម័យ១៩៧១ហ្នឹង ពួកខ្មែរក្រហម ពួកយួនហ្នឹងហ៎ា វាយមកដល់ត្រើងហ្នឹងហ៎ា ដល់ត្រើង រួចយើងភ័យហ៎ា ខ្ញុំកាលណុងរៀបចំម៉ូតូ រ៉ឺម៉កមួយដឹកឥវ៉ាន់ទៅនៅបុសខ្នុរ នៅនៅបុសខ្នុរមិនសុខមិនសាប់ ពួកធាវគីឡើងទៅ យើងធ្វើម៉ូតូដឹករ៉ឺម៉កហ្នឹងដឹកឥវ៉ាន់ទៅនៅស្រែវាល ស្រាប់ទៅដល់ខាងកើតស្ពឺបន្តិច ស្រាប់កប៉ាល់ហោះអាធាវគី អាទ្រុងជ្រូកហ៎ា អាខ្មៅធំ អាកប៉ាល់ហោះយកការហ្នឹងហ៎ា បាញ់! បាញ់ស្លាប់បងខ្ញុំមួយ ក្មួយបង្កើតខ្ញុំមួយ។ ក្មួយបង្កើតខ្ញុំអាយុ កាលណុងអាយុ២០ឆ្នាំ។

ក៖ ឆ្នាំណា? អ៊ុំចាំឆ្នាំទេ?

ខ៖ ឆ្នាំប្រហែល៧១!

ក៖ ប្រហែល៧១អ៊ុំ!

ខ៖ ហ្នឹងហើយ! បាញ់ទៅស្លាប់ ស្លាប់បងមួយ ហើយក្មួយមួយ ហើយដល់ក្រោយពីស្លាប់ កប់សព កប់អីរួចទៅ យើងចាកចេញពីណុងមក យើងឈប់នៅណុងហើយ យើងគេចមកផ្ទះយើងវិញហ៎ា អង្កាល់ណុង ផ្ទះយើងនៅខាងលន់នល់ទេ ប៉ុនមក វាអត់យាត់ដែរ យើងស្កាត់មកផ្ទះយើងវិញ។ ដល់ឆ្នាំ៧៣ដែលខ្ញុំការហ្នឹងហើយ មានពួកអាពតវាយមកដល់ភ្នំ មកដល់រោងចក្រ បែកគ្នាម៉ង បែកគ្នាអាយើងនិយាយមិញហ្នឹង រួចដល់ទៅនៅជាមួយអាពត ហ៊ូ! អានោះក៏មហាលោតភ្លោះទៀតហើយ។ ហើយអាពតហ៎ា ខ្ញុំស្លាប់ បើសិនជាស្លាប់មិនដឹងជាស្លាប់ប៉ុន្មានដង ប៉ុនដូចជាអាយុ មិនអស់ហ៎ា។

ក៖ អូខេ! ប្រហែលពីមុនចូលដល់ហ្នឹង ចង់សួរអ៊ុំបកទៅក្រោយបន្តិច ទាក់ទងនឹងការរៀនសូត្រ។ ពីមុនសម័យប៉ុល...ឥឡូវសម័យប៉ុលពត អ៊ុំអាយុប៉ុន្មានអ៊ុំ?

ខ៖ សម័យប៉ុលពត ចាប់ពីឆ្នាំ៧៣ ខ្ញុំអាយុ២៤មិញហ្នឹង។

ក៖ ២៤! ហើយចុះពីមុនហ្នឹង អ៊ុំរៀនសូត្រដល់ណាដែរ? ពីមុនប៉ុលពត?

ខ៖ អូ! រៀនត្រឹមបានឌីប្លូម។

ក៖ ឌីប្លូមអ៊ុំន៎?

ខ៖ ហើយហ្នឹង!

ក៖ ហើយដូចនៅកាលបឋមសិក្សាអី អ៊ុំរៀននៅសាលាណាអ៊ុំ? ចាំឈ្មោះសាលា?

ខ៖ សាលាអង្គញជី!

ក៖ បឋមសិក្សាអង្គញជីចឹងន៎ អ៊ុន៎?

ខ៖ ហ្នឹងហើយ!

ក៖ ហើយចូលដល់មធ្យមសិក្សា អនុវិទ្យាល័យ?

ខ៖ អនុវិទ្យាល័យហេ៎?

ក៖ ចាស!

ខ៖ អនុវិទ្យាល័យ ដូចនៅឆ្នាំ៦៣ មិនដឹងទេ។ ៦៣ប្រលងគោងគួរ។

ក៖ គោងគួរហ្នឹងម៉េចអ៊ុំ?

ខ៖ គោងគួរហ្នឹង...ពីដើមគេមានអាថ្នាក់អញ្ចេក គេប្រលងជម្រុះ ជម្រុះដូចសម័យរដ្ឋកម្ពុជាចឹង ហា៎ ពីណាប្រលងជាប់កៅអីបានរៀន ឌីប្លូមហ្នឹងហា៎ បានបានរៀនបន្តហើយមានសិទ្ធិប្រលងចូលធ្វើគ្រូអីបាន។

ក៖ ចាស!

ខ៖ រួចអង្គាលជំនាន់សីហានុហ្នឹង ថ្នាក់ទី...កាលរៀនណុងគេរាប់ត្រឹមពីថ្នាក់ទី១២ទៅហា៎ ១២ ១១ ដល់ទី៧ចាប់បឋមហា៎ណា៎ ដល់ថ្នាក់ទី៦ហ្នឹងរៀនប្រលង គោងគួរ ប្រលងហ្នឹងបើធ្លាក់ យើងអត់បានរៀនទេ យើងនៅរៀនបឋមដដែល យល់ទេ?

ក៖ ចាស!

ខ៖ ហើយចឹង យើងប្រលងទៅជាប់ បើបានយើងរៀនបន្តទៀត។

ក៖ អញ្ចឹងអ៊ុំរៀនចប់វិទ្យាល័យទេ ពេលប៉ុលពតចូល?

ខ៖ នៅឆ្នាំនេះ ខ្ញុំឈប់ហើយ ឆ្នាំ...

ក៖ ត្រឹមឌីប្លូមអ៊ុំន៎?

ខ៖ ជាប់ឌីប្លូមហ្នឹងឈប់រៀនហើយ។

ក៖ ក៏ឈប់!

ខ៖ ហ្នឹងហើយ!

ក៖ ឈប់ទៅ ហើយអ៊ុំជាប់ឪប្លូមហ្នឹងនៅឆ្នាំណា? ចាំទេអ៊ុំ?

ខ៖ នៅឆ្នាំក្បែរ៦៦។

ក៖ ៦៦ (១៩៦៦)! ហើយចឹងចន្លោះពេលហ្នឹង រហូតដល់អ៊ុំជាប់ឪប្លូមរហូតដល់ប៉ុលពតចាប់ផ្តើមហ្នឹង ចន្លោះពេលហ្នឹងអ៊ុំធ្វើអី?

ខ៖ អូ៎! រត់ម៉ូតូ! យើងរត់ម៉ូតូឌុបហាំ យើងរត់ម៉ូតូ។ យើងអត់មានការងារអីធ្វើទេ ដល់ពេលណុងវា យើងម្នាក់ៗរកស៊ីរៀងខ្លួនហាំណាំ។

ក៖ ហើយអញ្ចឹងឥឡូវដល់ជំនាន់ប៉ុលពត ពេលហ្នឹងអ៊ុំធ្វើអី? គេប្រើឱ្យយើងធ្វើអី?

ខ៖ ជំនាន់ប៉ុលពត យើងធ្លាប់វែកដី

ក៖ លើកទំនប់ ឬក៏ម៉េចអ៊ុំ?

ខ៖ លើកទំនប់ ជីកប្រឡាយ ស្ទូងស្រូវ ស្អីក៏ដោយ យើងហៅធ្វើទាំងអស់ យើងអត់មានថាចេះមិនចេះទេណា បើវាឱ្យយើងធ្វើអី យើងធ្វើហ្នឹងហើយ។ គ្រាន់ទំនប់ត្រួយចេក ទៅប៉ុន្មានខែទំនប់ត្រួយចេកយើង សង្កាត់ទ្រានហ្នឹងហាំ យើងវែកដីរួចរបស់យើងហើយ យើងទៅជួយសង្កាត់គេទៀត ពិបាកណាស់។

ខ៖ ចាស! ហើយអញ្ចេក អ៊ុំរៀនបានគួរសមដែរដល់ឪប្លូមជំនាន់ណុង ចឹងដល់ពេលជំនាន់ប៉ុលពត អ៊ុំខ្លាចទេ ឬក៏ត្រូវលាក់ប្រវត្តិ ឬក៏ម៉េចវិញ?

ក៖ កាលជំនាន់អាពត គេមិនដែលសួរយើងថា ដែលធ្វើអី ធ្វើអីផង អត់ដែរទេ ប៉ុនពេលមួយ អ៊ុំចេះតែនឹកឃើញថា មិនគួរណាយើងធ្វើចេះទេហាំ។

ក៖ ចាស!

ខ៖ ពេលណុងទៅធ្វើស្រែប្រាំងនៅរូងក្រពើហាំ រូងប្រពើនៅខាងលិចកៀនជ្រៃហាំ។ ស្រាប់ប្រធានភូមិឱ្យខ្ញុំទៅវាស់ដីនៅតាមស្រែប្រាំងហ្នឹង មានទំហំប៉ុន្មាន។ ស្រាប់អ៊ុំព្រមទៅវាស់ អើគេប្រើហើយមិនទៅ ទៅវាស់ជាមួយគេហ្នឹងហាំ ហើយគេឱ្យគិតជាហិចតាឱ្យគេទៀត ន៎អាគិតជាហត្ថាហ្នឹងបានប្រហោងពោះមែនទែន រួចបាននឹកថាយើងមិនគួរធ្វើចេះសោះ។

ក៖ ចាស!

ខ៖ ព្រោះជំនាន់ណុងអ្នកចេះគិតជាហត្ថាជាផ្ទៃក្រឡាអត់មានមនុស្សចេះទេ។

ក៖ ហើយអ៊ុំចេះ?

ខ៖ អើយើងរៀនបានច្រើនហើយ មានអីមិនចេះ យើងចេះ។ ចេះហ្នឹង ដូចអ៊ុំថាស្តាយមិនគួរធ្វើចេះហាំ យើងធ្វើចេះ ដល់អាពេលណុង អាពតរកតែមុខអ្នកចេះហ្នឹង គ្រាន់តែអាំងអន្សមអាំងហ្នឹង ក៏វាថាអនុធនដែរ មិនបាច់ដល់សិស្សទេ។

ក៖ អនុធនហ្នឹងម៉េចអ៊ុំ?

ខ៖ អនុធនហ្នឹងយើងមានន័យថាវណ្ណៈខ្ពស់ហាំស រួចវាស្អប់ណាស់អាវណ្ណៈខ្ពស់ហ្នឹងហាំ គេថាអាវណ្ណៈជិះជាន់ហាំ ពេលមួយនោះ អ៊ុំនិយាយដល់នៅឆ្នាំប្រហែល៧៧ គេកំពុងតែវាយគ្នាវាយសម្លាប់មនុស្សខ្លាំងហាំណាំ ស្រាប់អ៊ុំទៅធ្វើស្រែប្រាំង ពេលថ្ងៃសម្រាកពីធ្វើការហ្នឹងមកយើងដើររកឃ្មុំកាលណុងហាំ អាឃ្មុំយើងហ្នឹងហាំ ដើរទៅរកឃ្មុំស្រាប់តែទៅជួបអាខ្មែរសដែលខ្ញុំនិយាយថាខ្មែរសខ្មែរក្រហមមិញនេះ ទៅជួបណុងវាហាមយើង វាសួរយើងសួរប្រវត្តិរូបទាំងអស់ ហើយវាហាមយើងមិនឱ្យប្រាប់ពីណាទាំងអស់ សូម្បីម្តាយឬប្រពន្ធ ឱ្យប្រាប់ដែរ វាថាប្រាប់ទៅមនុស្សម្នាក់ជិត១០០មិនអាចប្រាប់គេ។ ស្រាប់បានតែ៣ថ្ងៃ ប្រធានភូមិហៅខ្ញុំទៅសួរមុនគេម៉ង ដល់ហៅទៅសួរ សួរថាមិត្តឯមានជួបខ្មាំងអត់។ ចឹងយើងឆ្លើយមិច? ជួបខ្មាំងអីអត់ហ្នឹង យើងត្រូវឆ្លើយឱ្យលឿនហាំ បើអេអូៗ ងាប់ហើយអត់រស់ទេ អេអូ ថាយើងភរវាអីចឹងទៅណាំ។

ក៖ ចឹងបើគេសួរភ្លាម យើងត្រូវឆ្លើយភ្លាមអ៊ុំន់?

ខ៖ ឆ្លើយភ្លាម! ទៅអ៊ុំហ្នឹងឆ្លើយភ្លាម អត់ឱ្យយូរទេ យើងគិតក្នុងចិត្តយើងស្រេចហើយណាំ តែយូរវាលែងទុកចិត្តយើង ថាយើងភរអីណាំ ដល់ខ្ញុំថាជួប អ៊ុំប្រាប់គេថាជួបចឹងណាំ រួចវាសួរតទៀត “ចឹងហេតុអីបានមិត្តឯអត់ប្រាប់អង្គការ?” អ៊ុំប្រាប់វាថា អង្កាលជួបវា វាហាមដាច់ខាតអត់ឱ្យនិយាយ តែប្រពន្ធកូនម្តាយក៏អត់ឱ្យនិយាយដែរ ដូច្នេះខ្ញុំម៉េចហ៊ានប្រាប់ ដូចថា ចុះទឹកក្រពើឡើងលើខ្លា អត់បានទេ ថាចឹងហាំ។ រួចឱ្យខ្ញុំធ្វើម៉េច? ខ្ញុំមិនប្រាប់ក៏ខុស តែប្រាប់វាសម្លាប់ខ្ញុំ ចឹងអាហ្នឹងគេថាចុះទឹកក្រពើឡើងលើខ្លា តើឱ្យខ្ញុំធ្វើម៉េច? ចឹងយើងដោះសារ...

## វីដេអូទី៣

ខ៖ ថាយើង...គេហៅយើងទៅសួរថាខ្មាំងអីអត់ អញ្ចឹងយើងត្រូវឆ្លើយប្រាប់គេថាជួប ព្រោះយើងលាក់អត់បានទេ បើវាដឹងហើយបានវាសួរយើងហាំ ដល់អញ្ចឹងទៅនែ៎ស្អែកឡើង វាហៅ

យើងទៅសួរទៀត ហៅទៅសួរសំណួរដដែលៗហ្នឹង បីដង ហើយយើងនៅតែឆ្លើយដដែលៗហ្នឹង ទាំងបីដង។

កៈ សំណួរហ្នឹង សំណួរអីអ៊ុំ?

ខៈ សំណួរថា មិត្តឯងមានជួបខ្មាំងអីអត់ហ្នឹងហាំ។

កៈ ចាស!

ខៈ យើងថាជួប តែយើងហាមមិនឱ្យនិយាយ យើងប្រាប់វាថាចឹងហាំ សួរយើងដល់៣ដង ៣ដង យើងឆ្លើយដដែល ដល់ឆ្លើយដដែលចឹង ស្រាប់ថ្ងៃទី៤ ថ្ងៃទី៤វាហៅយើងទៅម្តងទៀត ស្រាប់វាតម្លើងយើងទៅជាកម្មាភិបាល វាទុកចិត្តយើងវិញហាំ យើងទុកចិត្តថាយើងមនុស្សទៀងត្រង់ហើយ និយាយប្រាប់ត្រង់ពីមូលហេតុដែលមិនប្រាប់អង្គការ ព្រោះវាហាម ខំវាសម្លាប់ចោល ដល់ចឹងយើងអត់ហ៊ាប្រាប់ ដល់ចឹងទៅវាហៅយើងទៅលើកក្រោយទី៥ហ៎ មិនមែនត្រឹមទី៤ទេ ទី៣ហើយទី៤នៅពេលប្រជុំរួមភូមិ នៅនឹងស្រែហាំ វាហៅយើងទៅសួរខ្ញុំថាស្លាប់ហើយលើកទីបួនហ្នឹង ព្រោះគេមកផ្ទះអត់ហើយ នៅតែយើងម្តង មកដល់ផ្ទះគេហៅទៅវិញ។ រួចពីអាហ្នឹងទៅ លើកទី៥ លើកទី៥ វាតម្លើង វាថាៈ “មិត្តឯងឡើងជាកម្មាភិបាល។” ឱ្យយើងធ្វើប្រវត្តិរូប ដល់ធ្វើប្រវត្តិរូបសួរយើងធ្លាប់រៀនដល់ណា?

កៈ អ៎! វាសួរអ៊ុំនែ៎។

ខៈ សួរ! រួចទៅយើងថារៀនបានតិចតួចអីចឹងហាំ ដល់ថារៀនបានតិចតួច វាសួរទៀតថាពីក្មេងហ្នឹងធ្លាប់រកស៊ីធ្វើអី? អត់ធ្វើអីផងនៅជាសិស្សហ្នឹង ប្រាប់វាចឹងហាំ ថាខ្ញុំជាសិស្សហ្នឹង។ រួចចុះបងប្អូនជីដូនមួយ? យើងធ្វើឱ្យដូចថាប្រវត្តិរូបយើងធ្លាក់ហាំ ថាបងប្អូនជីដូនមួយធ្វើការរោងចក្រ ប្រាប់វាថា អូនែ៎ប្រវត្តិរូបមិត្តឯងអនុច។ អនុចនមានន័យថាយើងមានប្រាក់ខែស៊ីហាំ មានអាគំនិតខ្ពស់ហាំ ចឹងយើងអត់បានកម្មាភិបាល ធ្លាក់។ ប៉ុនយើង យើងធ្វើឱ្យធ្លាក់ហ្នឹងហាំ ពេលណាយើងជាប់...

កៈ ការពិតវាជាល្បិចមួយរបស់គេដើម្បីចង់ដឹងពីប្រវត្តិរបស់យើងហាំ។

ខៈ សួរប្រវត្តិហ្នឹងដើម្បីឱ្យឡើង ប៉ុន្តែបើយើងឡើង អាពួកនិរតីហ្នឹងមក អាប្រធានហ្នឹង សម្លាប់ចោលមុខគេហើយ។ ចឹងដឹងផែនការវា យើងធ្វើមិចកុំឱ្យប្រវត្តិរូបហ្នឹងជាប់ យើងត្រូវគិត ភ្លេចភ្លាមៗ បើសិនយើងធ្វើឱ្យជាប់ យើងត្រូវស្លាប់ ស្លាប់នៅពេលបន្ទាប់មកទៀតហ្នឹងហាំ អញ្ចឹងយើងធ្វើម៉េចអត់ឱ្យជាប់ទេ បើជាប់កម្មាភិបាលហ្នឹង យើងងាប់ហើយ។ រួចទៅបានគេឡើងទៅ

២នាក់ ជាប់ម្នាក់ ហើយនៅខ្ញុំរួចខ្លួន រួចខ្លួនប៉ុនក្រោយមកអាប្រធានភូមិដែលតែងតាំងយើងអីសួរយើងទាំងប៉ុន្មាន គេយកវាទៅសម្លាប់ចោលអស់ យើងរួចខ្លួច យើញដេស។

កៈ អញ្ចឹងនៅជំនាន់ហ្នឹងអ៊ុំថាគេតម្លើង ចឹងអ៊ុំបានធ្វើកម្មាភិបាល...

ខៈ អត់បានឡើងទេ យើងធ្វើឱ្យធ្លាក់។

កៈ អូខេ! អញ្ចឹងបន្ទាប់ពីហ្នឹងមកទៀត អ៊ុំធ្វើអីនៅសម័យណុង?

ខៈ ធ្វើជាប្រជាពលរដ្ឋធម្មតា។

កៈ គេប្រើយើងទៅធ្វើស្រែអីចឹង?

ខៈ គេប្រើយើងទៅធ្វើអី យើងទៅជាមួយគេជាមួយឯងចឹងទៅ។

កៈ ចាស! ហើយដូចជាបងប្អូនអី ក្រុមគ្រួសារអីអត់នៅជាមួយគ្នាទេ?

ខៈ អត់ទេ! បែកគ្នា យើងមានប្រពន្ធទៅ យើងនៅជាមួយប្រពន្ធហើយ។

កៈ ចាស! ប៉ុន្តែគេឱ្យនៅជាមួយប្រពន្ធដែរសម័យហ្នឹង?

ខៈ ឱ្យនៅតើ! ពេលថ្ងៃទៅធ្វើការ ហើយយប់...

កៈ ជួបគ្នាទៅ

ខៈ យើងមានផ្ទះយើងវិញ មកផ្ទះយើងវិញ រៀងៗខ្លួនចឹងហាំ។

កៈ ហើយដូចជាយើញថានៅសម័យណុង អ៊ុំជួបការលំបាកអីខ្លះអ៊ុំ?

ខៈ ហ៊ូ លំបាកហូបអត់ឆ្អែត ធ្វើការច្រើន ច្រើនពេកហាំ។ ធ្វើមានអាធ្វើទាំងយប់ទៀតណាំ ទៅច្រូតស្រូវទាំងយប់ ភ្លឺឡើងទៅដកស្ទូវស្រែប្រាំងទៀត អត់បានទេបានពួនទេ ប៉ុន្មានថ្ងៃជិតចប់ហ្នឹង អាបានជួបទេប៉ុន្មានថ្ងៃជិតចប់ហ្នឹង។

កៈ ហើយចុះពេលដែលចប់មក ពេលដែលវាយបែកមក អ៊ុំចាប់ផ្ដើមធ្វើអី?

ខៈ ពេលដែលវាយបែកមក ខ្ញុំរកស៊ីបិតស្រា បិតស្រាយើងធម្មតាហ្នឹង បិតស្រាទៅ យើងមានមុខរបរ យើងចិញ្ចឹមជ្រូកមាន់ទាស្អីៗហ្នឹង និយាយទៅមុខរបររកស៊ីយើង និយាយទៅ។ ហើយបិតស្រាបន្តិចទៅ គេចាប់ធ្វើទាហាន គេរើសទាហានធ្វើកងទ័ពហាំ កាលណុងដល់មួយសារទៀតហើយ ខ្ញុំកាលណុងគេឱ្យចាប់ឆ្នោត ដល់ចាប់ឆ្នោតវាអត់ជាប់ហាំ អត់ជាប់ទេ វារួចខ្លួន

ដល់រួចខ្លួន ខ្ញុំទៅពឹងនរគបាលម្នាក់ដែលស្គាល់គ្នាហ្នឹងថា៖ “ខ្ញុំចាប់ឆ្នោតអត់ជាប់ទេ ខ្ញុំភ័យណាស់។” អញ្ចឹងអាននរគបាលវាថាទៅភ័យអី វានិយាយថាចឹងហាំ បើអញ្ចឹងម៉េចមិនភ័យ ខ្ញុំថាចឹងហាំ បើស្គាល់គ្នាហាំ “អើបើមិនចង់ធ្វើនរគបាលមកខ្ញុំម៉ង ខ្ញុំជួយ។” អញ្ចឹងពីណុងមក យើងសុំគេបាលធ្វើនរគបាល ឱ្យលុយគេហាំណា ឱ្យអង្កាលណុងអស់៧រយ ៧រយហ្នឹងស្មើនឹង២ជីជាង ដល់ធ្វើនរគបាល វាឱ្យយើងចាប់ អើនរគបាលវាមានតួនាទីហើយណា ចាប់សណ្ដែកល្ង ដែលប្រជាជនចាប់យកទៅលក់អីចឹងហាំ យើងអត់ចូលចិត្តរឿងធ្វើអាក្រក់ជាមួយអ្នកដ៏ទៃ អត់ចាប់ អត់ចាប់ទទួលគេរើសធ្វើគ្រូម្ដង។

ក៖ ចេញពីនរគបាលមកអ៊ុំណាំ?

ខ៖ មិនទាន់ចេញទេ។ នៅនរគបាលប៉ុនគេជ្រើសរើសគ្រូបង្រៀនហាំ ហើយចឹងអ៊ុំដាក់ទៅគ្រូបង្រៀនវិញ ដាក់ពាក្យហាំ ពាក្យប្រលងអីជាមួយគេត្រឹមត្រូវចឹង ទៅជាប់មែន ជាប់នរគបាលអ៊ូ! ជាប់នរគបាលអី ជាប់ធ្វើគ្រូវិញ ហើយទៅយើងធ្វើគ្រូតាំងពីណុងរហូតមក។

ក៖ មកដល់សព្វថ្ងៃហ្នឹងទៅ?

ខ៖ ដល់រាល់ថ្ងៃហ្នឹង។

ក៖ គ្រូហ្នឹង អ៊ុំបង្រៀនកម្រិតអីដែរ?

ខ៖ កម្រិតបឋម!

ក៖ បឋមអ៊ុំណាំ!

ខ៖ ហ្នឹងហើយ!

ក៖ បង្រៀនហ្នឹងមុខវិជ្ជាអីខ្លះអ៊ុំ?

ខ៖ ហាំកអាហ្នឹងទូទៅតើ។ បង្រៀនតាំងពីរៀនអាន គណិត វិទ្យសាស្ត្រអនុវត្ត គំនូរ សុភាវធម៌ អាហ្នឹងចម្រុះហាំ។ មិនមែនដូចនៅមធ្យម គេបង្រៀនតែឯកទេណា គេយកតែមួយទេ។

ក៖ ចាស!

ខ៖ ហើយចឹងនេះសរុប...

ក៖ អត់អីអ៊ុំតទៀតទៅ។

ខ៖ ហើយចឹង យើងធ្វើគ្រូហ្នឹងជាប់ទៅគ្រូល្អ គ្រូអីទៅទៀត រឿងច្រើនហាំ គេធ្វើប្រធានក្រុម ប្រធានអីចឹងហាំ ប្រធានក្រុមបច្ចេកទេស គ្រប់ផ្នែក។ គ្រូហ្នឹងតាមតែគេមើលសមត្ថភាពយើងហាំ។

ក៖ ចាស! ហើយចុះប្រពន្ធអ៊ុំគាត់ធ្វើអី?

ខ៖ ប្រពន្ធបិតស្រាមិញហ្នឹង។

ក៖ ដល់ពេលមកដល់បច្ចុប្បន្នហ្នឹង នៅតែប្រកបរបរហ្នឹងដដែល?

ខ៖ ទេឥឡូវហ្នឹងលែងបិតហើយ ទៅនៅជាមួយកូននៅសៀមរាបណំ។

ក៖ ពីមុនដូចគាត់លក់ឥវ៉ាន់ដែរអ៊ុំនេំ?

ខ៖ ប៉ុនឈប់លក់ទៅនៅជាមួយកូនហើយ។

ក៖ ចាស! អូខេ ហើយដោយសារអ៊ុំធ្វើគ្រូបង្រៀន បានរយៈពេលប៉ុន្មានឆ្នាំហើយ តាំងពីធ្វើមក?

ខ៖ ២៨ឆ្នាំ!

ក៖ ២៨ឆ្នាំ!

ខ៖ ចូលនិវត្ត២៨ហ្នឹង។

ក៖ ចាស! ចឹងចង់សួរអ៊ុំបន្តិចដោយសារធ្វើគ្រូបង្រៀនយូរមកហើយអ៊ុំនំ ក្នុងអាជីពជាគ្រូបង្រៀនហ្នឹងមានកន្លែងណាដែលអ៊ុំចូលចិត្តជាងគេពីការងាររបស់អ៊ុំ?

ខ៖ ចំនុច អ៊ុំចូលចិត្តស្អីដែលផ្តល់ចំណេះឱ្យគេ ចូលចិត្តណាស់ ព្រោះអ៊ុំចង់បណ្តុះបណ្តាលមនុស្សហាំ អត់ចឹងអាធ្វើ ឃើញគេល្ងង់យើងសប្បាយចិត្ត អត់ចង់ចឹងទេណា យើងចង់បង្រៀនវាឱ្យចេះ។

ក៖ ចាស! ហើយអញ្ចឹងចង់សួរអ៊ុំបន្តិច។ សួរថាពីក្មេងមកដល់បច្ចុប្បន្នហ្នឹង ជីវិតអ៊ុំបានប្រាប់ប្រែយ៉ាងម៉េចខ្លះ?

ខ៖ អូ៎! ពីក្មេងមកឥឡូវហ្នឹង អ៊ុំដូចថាសំណាងចុះ សំណាងត្រង់ចូលព្រះវិហារហ្នឹង ព្រះប្រទានពរឱ្យយើង ប្រទានពរយ៉ាងម៉េច? ហូបអត់មានខ្វះខាតអីម៉ង ពីមុនយើងភ័យលុយកាក់ ដល់ឥឡូវអត់មានខ្វះទេលុយកាក់នោះ គ្រាន់តែមួយចាយ ប្រាក់សោតធននិវត្តយើងមាន ហើយកូនវាធានាយើងទៀត ខ្វះអី យើងប្រាប់វាទៅ វាឱ្យមកហើយ ចឹងមានអីដែលត្រូវពិបាក។

កៈ ហើយអ៊ុំមិញខ្ញុំបានសួរពីកូនរបស់អ៊ុំទេ? អ៊ុំមានកូនប៉ុន្មាននាក់? ចាំ?

ខៈ អូ ភ្លេចកូន!

កៈ ចាស!

ខៈ អ៊ុំមាន៤ ហើយស្រី២ប្រុស២។

កៈ អ៊ុំរៀបរាប់ឈ្មោះគាត់បន្តិចបានទេអ៊ុំ?

ខៈ មុនដំបូង ចន្ទ្រា ហួតចន្ទ្រា ហួត គន្ធា ហួត ចិន្តា ហួត វ៉ាន់ដូ មាន៤។ ស្រី២ប្រុស២។
កៈ ពួកគាត់អាយុប៉ុន្មានអ៊ុំ?

ខៈ ឥឡូវបងអាយុប្រហែលសែជាងហើយ ហើយអាប្អូននោះអាយុចន្លោះប្រហែល៣៧ អាប្អូន ៣៧ កូន៣៧ហាំ។

កៈ ចាស!

ខៈ អាកូនទី៣ ប្រហែលជា៣៩ឆ្នាំហ្នឹងហើយ។

កៈ ហើយពួកគាត់រៀបការអស់ហើយអ៊ុំនេះ?

ខៈ នៅសល់អា៣៩មួយ មិនទាន់រៀបការ។ វាអត់ចូលចិត្តប្រពន្ធកូនអី ចឹងវានៅលីវ។

កៈ ចាស! ហើយចង់សួរអ៊ុំបន្តិច អ៊ុំដែលមានជំនាញអីអ៊ុំចេះមកពីឪពុកម្ដាយមកណាំ?

ខៈ ទេ ដូចអត់មានផង!

កៈ អត់មានទេអ៊ុំន់។

ខៈ ឪពុកម្ដាយខ្ញុំលក់ដូរ ហើយខ្ញុំអត់មានជំនាញលក់ដូរសោះ ដូចអត់ចិត្ត។ របៀបថាដូចកូនចិនមិនស្រឡាញ់ ស្រឡាញ់កូនខ្មែរ (សើច)។

កៈ ចុះចំណូលចិត្តរបស់អ៊ុំវិញ អ៊ុំចូលចិត្តធ្វើអី?

ខៈ ចូលចិត្តធ្វើគ្រូហ្នឹង។

កៈ ចាស! ដូចថាពេលទំនេរពីការងារអីចឹង ដែលអ៊ុំរួចរវល់ចឹងណាំ មានពេលទំនេរអ៊ុំចូលចិត្តធ្វើអី?

ខ៖ អូ! ចូលចិត្តអានសៀវភៅ ចូលចិត្តស្អី អត់នៅទំនេរបានទេ ចូលចិត្តអានសៀវភៅ ចូលចិត្តលេងអុកឈើត្រង់អីចឹងឱ្យតែទំនេរ ហើយឱ្យនៅស្ងៀម អត់នៅស្ងៀមទេ។ អត់ថាមួយថ្ងៃនៅផ្ទះដេកសំកុកដល់ល្ងាចយប់ម៉ង អត់ចឹងទេ។

ក៖ មិញថាអ៊ុំចូលចិត្តលេងអុកឈើត្រង់ អ៊ុំប្រាប់បន្តិចបានទេ ម៉េចអុកឈើត្រង់ហ្នឹង?

ខ៖ អុកឈើត្រង់ហ្នឹង ដូចយើងលេងវ៉ែក ស្គាល់វ៉ែកទេ?

ក៖ ស្គាល់អ៊ុំ!

ខ៖ មានក្រឡា៦៤ដូចគ្នាចឹង ប៉ុនវិធីសាស្ត្រ វិធីដើរអត់ដូចគ្នាទេ។ វាមានកូនម្ខាង១៦ អាកូនជួរមុខគេហៅត្រី អាហ្នឹងដូចប្រជាពលរដ្ឋចឹង អត់មានឋានៈ បុណ្យសក្តិអីទេ។ បើអាជួរក្រោយហ្នឹង ទីមួយស្តេច អាហ្នឹងកំពូលហើយណា អាហ្នឹងគេហៅខុន ហើយបន្ទាប់មកនាង នាងហ្នឹងដូចប្រពន្ធស្តេច បន្ទាប់មកគោល គោលហ្នឹងដូចមេទ័ពជើងគោកចឹងហា៎ ហើយសេះមេទ័ពប្រដេញ ហើយទូកដូចមេទ័ពជើងទឹកចឹង ហើយក្នុងកូនទាំងអស់ហ្នឹងអត់មានដើរដូចគ្នាទេ មានរបៀបគេដើរទៀត ទាល់តែយើងរៀនបានចេះ បើអត់រៀនអត់ចេះទេ។

ក៖ អញ្ចឹងអ៊ុំចេះលេងអុកឈើត្រង់ហ្នឹង រៀនមកពីណាដែរ?

ខ៖ មើលគេមុនដំបូង មើលគេ សួរគេទៅ យូរទៅឱ្យតែចំណូលអី វាចេះអាហ្នឹងហើយ។ សួរគេសួរឯងទៅចេះហើយ ប៉ុនមុននឹងចេះហ្នឹងប្រើពេលយូរហា៎។

ក៖ ប្រហែលប៉ុន្មានឆ្នាំទៅបានអ៊ុំចេះ?

ខ៖ ចេះមិនយូរប៉ុន្មានទេ ប៉ុន្តែពេលដែលយើងយកឈ្នះដៃគូយើងទាល់តែយើងប្រើពេលយូរហើយឆ្លាតទៀត បើយើងអត់ឆ្លាតចាញ់តែគេហ្នឹង។

ក៖ ហើយអ៊ុំចេះលេងប៉ុន្មានឆ្នាំហើយ?

ខ៖ យូរ តាំងពីកម្លោះ!

ក៖ (សើច) អូខេ! ចឹងយូរហើយអ៊ុំណ៎?

ខ៖ យូរហើយ!

ក៖ ហើយចុះក្រៅពីហ្នឹង ដូចជាល្បែងប្រជាប្រិយអីអ៊ុំចូលចិត្តទេ?

ខ៖ ទេ ដូចជាអត់ចូលចិត្តទេ! ដូចធុញវិញហាំ ប្រជាប្រិយដូចជាបោះឈូង ចោលអង្គុញអី វាដូចសុាំហាំ។

ក៖ អូខេ! ចុះចម្រៀង? ដូចអុំ...

ខ៖ ចម្រៀងចូលចិត្តអារឿងបទស្រគត់ស្រគុំហាំ សង់ទីម៉ងហាំ មិនចូលចិត្តអាបទឆ្កួតអាឡាក់អាឡើត គ្មានរកទិសតំបន់មិនឃើញ គ្មានក្បួនគ្មានខ្នាត អត់ចូលចិត្តទេ។

ក៖ ចុះដូចបទសម័យអត់ចូលចិត្តទេអុំន៎?

ខ៖ បទសម័យ ប៉ុន្តែវាមែនបទអាឌីជេរាល់ថ្ងៃ ឡោតក្បាលទាញចុះជើងបង្វិលអី ហ៎...អត់ទេ គ្មានរបៀបរបបយ៉ាងហ្នឹង អត់ចូលចិត្តទេ។ មិនមែនចេះតែចូលចិត្តទេណាំ។

ក៖ ចាសៗអុំ!

ខ៖ ឱ្យតែធ្វើអីលក្ខណៈថាមិនធម្មតាអត់ចូលចិត្តម៉ង។

ក៖ ចាស!

ខ៖ ស្អប់ទាំងមនុស្សទៀត ស្អប់ទាំងអ្នកធ្វើ។

ក៖ (សើច) អូខេ! ចុះដូចឧបករណ៍ភ្លេងអី អុំចេះលេងទេ? ឧបករណ៍ភ្លេងបុរាណ ភ្លេងសម័យអី?

ខ៖ អត់ចេះទេ! ចេះតែស្ដាប់ ចេះតែចូលចិត្តប៉ុណ្ណឹង បើរឿងជំនាញអត់មានទេ។

ក៖ ចុះក្នុងក្រុមគ្រួសារអុំ មាននរណាចេះទេ?

ខ៖ អត់ដែរណុង! អត់ទេ អត់មានពីណាចេះទេ។

ក៖ ចុះនិយាយពីម្ហូប ម្ហូបវិញ អុំចូលចិត្តម្ហូបអី?

ខ៖ ចូលចិត្តតែម្ហូបស្លការីអីហ្នឹង សម្លការីវាបានច្រើនមុខហាំ ឧបមាថាសម្លការីមួយមុខ យើងហូបនំប៉័ងក៏បាន ហូបជាមួយបាយក៏បាន ហូបជាមួយនំបញ្ចុកក៏បាន ហើយវាមានរសជាតិឆ្ងាញ់ អុំចេះស្លទៀត មិនមែនត្រឹមតែហូបទេ ចុងភៅពិសេសហាំ។

ក៖ សម្លការីអុំហ្អេ៎?

ខ៖ សម្លការីហាំ សួរអុំមើល តើស្លរបៀបម៉េចអុំចេះទៀត។

ក៖ អូល្អ! ហើយក្រៅពីសម្លការី មានសម្លអីទៀតដែលអុំចូលចិត្ត?

ខ៖ ក្រៅពីសម្លការី ដូចស៊ុបអីមានឆ្ងាញ់ម្យ៉ាងដែរ ស៊ុបវាពិសេសហា៎។

ក៖ អូខេ! ចឹងសួរបន្តិចទៀត សួរពីផ្ទះដែលអ៊ុំរស់នៅពីក្មេងមក ផ្ទះហ្នឹងមានលក្ខណៈយ៉ាងម៉េច?

ខ៖ ថាម៉េច?

ក៖ ផ្ទះពីក្មេងមកដែលអ៊ុំរស់នៅជាមួយឪពុកម្ដាយហា៎?

ខ៖ ផ្ទះក្បឿងពីរខ្នង ប៉ុនមុនដំបូងផ្ទះឈើ ផ្ទះតូចប្រកស្បូវទេ ដល់សម័យលន់នល់ហ្នឹង ប្រហែលឆ្នាំហុកជាងហ្នឹង ពុកខ្ញុំធ្វើបានផ្ទះក្បឿងពីរខ្នងបីខ្នង ហើយមាឡៅមានទៀត នៅជាន់ទីមួយទីពីរហា៎ អាហ្នឹងដូចថាយើងធ្វើបានផ្ទះខាងលើដូចផ្ទះពីរចឹងនិយាយទៅ ខាងក្រោមដូចផ្ទះថ្មចឹង ខាងក្រោមមួយទៀត។

ក៖ ហ្នឹងផ្ទះពីក្មេងមកនៅជាមួយឪពុកម្ដាយ?

ខ៖ នៅជាមួយឪពុកម្ដាយទេ។

ក៖ ចុះមកដល់ឥឡូវផ្ទះអ៊ុំមានលក្ខណៈយ៉ាងម៉េច?

ខ៖ ផ្ទះអ៊ុំឥឡូវ ផ្ទះក្បឿងហើយមានបន្ទប់ថ្មខាងក្រោម។

ក៖ ផ្ទះហ្នឹងជួលគេធ្វើអ៊ុំនេ៎?

ខ៖ ជួលតើ!

ក៖ អត់មានធ្វើខ្លួនឯងអីក៏អីអត់មានទេ?

ខ៖ អត់ទេ! អត់ចេះធ្វើជាង។

ក៖ អូខេ! អញ្ចឹងអ៊ុំប្រាប់ច្រើនពីបទពិសោធន៍រឿងលំបាកៗខ្លះក្នុងជីវិតជាពិសេសក្នុងសម័យប៉ុលពតអី ចុះដូចជាបទពិសោធន៍រីករាយអីមានទេអ៊ុំ? ដូចជានៅក្នុងជីវិតអ៊ុំគិតថាវាជាបទពិសោធន៍ដែលអ៊ុំ ដែលធ្វើឱ្យអ៊ុំសប្បាយជាងគេមិនអាចបំភ្លេចបាន?

ខ៖ អ៊ូ៎! សប្បាយជាងគេគឺមានអាជីវិតយុវវ័យហ្នឹង មានស្អី។ សប្បាយជាងគេជីវិតយុវវ័យហ្នឹង។

ក៖ ចាស!

ខ៖ ពីណាក៏គេសប្បាយដែរអាជីវិតយុវវ័យហ្នឹង។

កៈ សប្បាយយ៉ាងម៉េចអ៊ុំ? អ៊ុំអាចប្រាប់បានទេ?

ខៈ វាអត់មានកង្វល់អីផងហ្នឹង។ អាហ្នឹងមិនសប្បាយ ចូលភាពសប្បាយហាំណាំ អត់មានខ្វល់ថា ហ្អេះ! អត់មានអីញាំុទេ មិនចឹង?

កៈ ចាស!

ខៈ ពីកម្លោះមានទៅគិតអី មែនអីយើងតើអ្នករកឱ្យ ចឹងវាសប្បាយហើយ មានស្អីទៀត។

កៈ ហើយចុះអឺ...ខ្ញុំសួរទាក់ទងនឹងរឿងសាសនាបន្តិចអ៊ុំ ដូចនៅជាមួយឪពុកម្ដាយអ៊ុំ ឪពុកម្ដាយអ៊ុំគាត់កាន់សាសនាអី? ឬក៏...

ខៈ សាសនាព្រះពុទ្ធតើ កាលណុងអត់មានសាសនាគ្រីស្ទផង។

កៈ អញ្ចឹងគាត់កាន់ព្រះពុទ្ធន៎ ឬក៏មានទំនៀមទម្លាប់សាសនាអីដែលធ្វើនៅក្នុងក្រុមគ្រួសារអីមានទេអ៊ុំ?

ខៈ អ៊ូ! អាហ្នឹងមិនមែនសាសនាទេ បែបទំនៀមទម្លាប់។ ទំនៀមទម្លាប់ ដូចជាខែសែនផ្ទះអី គេថា ចិនគេថាឆេងម៉េងហាំណាំ ចិនឆេងម៉េង អាហ្នឹងគាត់ធ្វើរាល់ឆ្នាំចឹង អាហ្នឹងដូចរំលឹកគុណឪពុកម្ដាយគាត់ចឹងណា ហ្នឹងនៅក្នុងក្រុមគ្រួសាររបស់អ៊ុំជាមួយឪពុកម្ដាយ។

កៈ ចុះអ៊ុំពីដើមឡើយ ពីមុនអ៊ុំកាន់សាសនាគ្រីស្ទហ្នឹង អ៊ុំខាងពុទ្ធសាសនាដែរអ៊ុំន៎?

ខៈ អត់មានកាន់ខាងណាផង។ ក្មេងធម្មតាហ្នឹងមានពុទ្ធសាសនាណា ទាល់តែគេចាស់បានគេទៅរកវត្តវ៉ា តែសម្រាប់យើងនៅក្មេង មានទៅវត្តអី។

កៈ ចាស! ចុះចឹងពេលណាដែលអ៊ុំចាប់ផ្ដើមស្គាល់សាសនាគ្រីស្ទ?

ខៈ អ៊ូ! នៅឆ្នាំ២០០។

កៈ ឆ្នាំ ២០០០ ហើយអ៊ុំ...

ខៈ ឆ្នាំ២០០ហ្នឹង ខ្ញុំចាំទាំងអែលឌើរទៀត អែលឌើរមេនទ្រុំ គាត់អ្នកផ្សព្វផ្សាយ ហើយមុនដំបូងអ៊ុំគ្រាន់តែសាកល្បងទេ ថា ចុម ឱ្យតែជនជាតិគេមកផ្សព្វផ្សាយហាក់ដូចជាចង់ដឹងហាំ រួចដល់ក្រោយពេលចង់ដឹង យើងឃើញថាសាសនានេះដឹកនាំយើងធ្វើល្អ។ ចឹងត្រង់ឃើញដឹកនាំយើងធ្វើល្អហ្នឹង យើងចេះតែនៅរហូតទៅ។

កៈ ចឹងដូចជាពេលដែលអ៊ុំផ្លាស់ប្រែសាសនាហ្នឹងមក អ៊ុំឃើញថាសាសនាដែលអ៊ុំចូលរាល់ថ្ងៃហ្នឹង គ្រីស្ទសាសនាហ្នឹង វាជះឥទ្ធិពលអីខ្លះនៅក្នុងជីវិតអ៊ុំ?

ខៈ សាសនាហ្នឹង ទីមួយយើងឃើញអាគោលការណ៍ល្អៗសិន។ គោលការណ៍ល្អហ្នឹង គេបង្រៀនយើងឱ្យចេះស្រឡាញ់គ្នា កុំចេះឆ្មើងឆ្មៃ ស្អីទាំងអស់ហ្នឹងដែលឱ្យខ្ញុំចូលចិត្ត។ ខ្ញុំមនុស្សទម្លាប់អាមិនឆ្មើងឆ្មៃហ៎ា ហើយខ្ញុំស្អប់អាភាពឆ្មើងឆ្មៃខ្លាំងណាស់ ព្រោះអត់ចូលចិត្តមនុស្សឆ្មើងឆ្មៃមនុស្សអាក្រក់ អ៊ុំមិនចូលចិត្តទេ។ អាហ្នឹងផ្តើមនៃការជឿហ៎ា ខ្ញុំអត់ចូលចិត្តទេ។ រួចបន្ទាប់ពីអាជំនឿតទៅទៀត ដោយសារមើលក្នុងគម្ពីរគ្រីស្ទបរិស័ទយើងហ្នឹង ព្រះគ្មានធ្វើអ្វីដែលថាអាក្រក់ទេ មានតែជួយមនុស្ស ក្រក៏ដោយមានក៏ដោយ មិនដែលព្រះអង្គ ប្រព្រឹត្តអាក្រក់សោះណា នៀកអាត្រង់ហ្នឹងហើយដែលអ៊ុំចូលចិត្ត រួចអាភាពជាក់ស្តែងដូចជាយើងសុខភាពអត់ល្អអី យើងខ្វះខាតដូចថាព្រះប្រទានឱ្យទៀតន៎ក ប្រទានដែលលុយជួយយើងហ្នឹងជាលុយព្រះហ្នឹងណា៎។

កៈ ចាស! អរគុណច្រើនអ៊ុំ! ចង់សួរអ៊ុំចុងក្រោយ ប្រសិនបើអ៊ុំមានអ្វីមួយផ្តាំផ្ញើរទៅកាន់កូនចៅអ៊ុំ ឬក៏កូនចៅជំនាន់ក្រោយទៀត ដោយសារអ៊ុំរស់នៅមានបទពិសោធន៍ច្រើន ហើយអ៊ុំរស់នៅឆ្លងកាត់សម័យកាលប៉ុន្មានសម័យកាលមកហើយ ចឹងអ៊ុំមានទាំងភាពល្អ មិនល្អ ចង់និយាយថាភាពសប្បាយ មិនសប្បាយច្រើន បទពិសោធន៍ច្រើន ចុះបើសិនជាចុងក្រោយអ៊ុំមានអីដើម្បីផ្តាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយទាក់ទងបទពិសោធន៍ដែលអ៊ុំឆ្លងកាត់នៅក្នុងជីវិត?

ខៈ ជំនាន់ក្រោយហ្នឹងហ៎ា អ៊ុំចង់ផ្តាំថាយើងជាមនុស្ស យើងត្រូវតែប្រព្រឹត្តល្អៗ កុំប្រព្រឹត្តអាក្រក់។ ហ្នឹងចាំបាច់ណាស់ណា យើងត្រូវតែធ្វើល្អ ហើយកុំរបៀបឆ្មើងឆ្មៃអត់ស្គាល់ថាអារបៀបគុណធម៌ សំខាន់ណាស់អាហ្នឹងហ៎ា ព្រោះឪពុកម្តាយខ្ញុំបង្រៀនខ្ញុំឱ្យប្រព្រឹត្តអំពើល្អហ្នឹងហ៎ា ចាំបាច់ណាស់។ អញ្ចឹងអាចំណុចហ្នឹងឃើញទេ វាអត់ខ្វះហើយ ហើយខ្ញុំមិនចូលចិត្តអារបៀបថា ឧបមាថាបានមានភ្លេចក្រ បានល្អភ្លេចពេលពិបាក អាហ្នឹងមួយអ៊ុំតែង...នាយកសាលារបស់ខ្ញុំហ្នឹង គេគ្រាន់ត្រឹមឋានៈនាយកសាលាវាមានអីធំប៉ុន្មាន តែគេមើលមកយើង គេឃើញយើងដូចកូនស្រមោចមួយចឹងហ៎ា ចឹងយើងអត់ចូលចិត្តទេ។ អ៊ុំរហូតដល់ប្តឹងទៀតនុះតែមិនចូលចិត្តទេណា៎ ប្តឹងនូវអំពើអាក្រក់ពួកវាហ្នឹងណា៎។

កៈ ចាស! អញ្ចឹងអរគុណច្រើនអ៊ុំសម្រាប់ថ្ងៃហ្នឹង ដែលបានឱ្យខ្ញុំសម្ភាស បានស្គាល់ជីវិតខ្លះរបស់អ៊ុំ ហើយអញ្ចឹងជាចុងក្រោយដោយសារពួកយើងមានតែប៉ុណ្ណឹង។